# ព្រះរាជក្រម

នស/រកម/១០០៩/០២០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់អាចពិនិត្យ និងឱ្យយោបល់តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញបាន ហើយ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើ
# កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

**មាត្រា ១.-**

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន ដែលបានចុះហត្ថលេខានៅឆាអាម ព្រះរាជាណាចក្រថៃឡង់ដ៍ នាថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធី ដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

**មាត្រា ៣.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៩

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម/១០០៩/០៣២ **នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ:៩៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# កិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

រដ្ឋាភិបាលនៃព្រុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ម៉ាឡេស៊ី សហភាពមីយ៉ាន់ម៉ារ សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ជារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ("អាស៊ាន") ដែលនៅក្នុងកិច្ចព្រមព្រៀងនេះ ហៅថា ("រដ្ឋសមាជិកទាំងអស់") ឬរដ្ឋតែមួយហៅថា ("រដ្ឋសមាជិក")

**រំលឹកឡើងវិញ** នូវសេចក្តីសំរេចនៃកិច្ចប្រជុំរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ានលើកទី៣៩ ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ ដើម្បីកែសំរួលឡើងវិញនូវកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន ដែលបានចុះហត្ថលេខានៅទីក្រុងម៉ាកាទី ប្រទេសហ្វីលីពីន នៅថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៩៨ ("កិច្ចព្រមព្រៀង AIA") ដូចដែលត្រូវបានធ្វើវិសោធនកម្ម ឱ្យទៅជាកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយមួយ ដោយសំឡឹងឆ្ពោះទៅមុខជាមួយនឹងការកែលំអទ្រង់ទ្រាយ និងប្បញ្ញត្តិនានា ដែលអាចប្រៀបធៀបបានជាមួយនឹងការអនុវត្តន៍ដ៏ប្រសើរជាលក្ខណៈអន្តរជាតិក្នុងទិសដៅបង្កើនការវិនិយោគនៅក្នុងអាស៊ាន និង ធ្វើឱ្យប្រសើរឡើងនូវភាពប្រកួតប្រជែងក្នុងការទាក់ទាញវិនិយោគចូលក្នុងអាស៊ាន

**ទទួលស្គាល់** នូវកំរិតខុសគ្នានៃការអភិវឌ្ឍក្នុងអាស៊ាន ជាពិសេសរដ្ឋសមាជិក ដែលមានការអភិវឌ្ឍតិចតួចដោយតម្រូវឱ្យមានភាពទន់ភ្លន់ខ្លះ រាប់បញ្ចូលទាំងប្រព្រឹត្តិកម្មពិសេស និងដោយឡែក ដូចដែលអាស៊ានកំពុងធ្វើដំណើរឆ្ពោះទៅរកអនាគតមួយ ដែលធ្វើសមាហរណកម្មជាមួយគ្នា និងពឹងអាស្រ័យគ្នាទៅវិញទៅមកកាន់តែច្រើនឡើង

**បញ្ជាក់អះអាងឡើងវិញ** នូវសេចក្តីត្រូវការដើម្បីធ្វើដំណើរឆ្ពោះទៅមុខ ពីកិច្ចព្រមព្រៀង AIA និងកិច្ចព្រមព្រៀងអាស៊ាន សំរាប់ការជំរុញ និងការការពារវិនិយោគ ដែលបានចុះហត្ថលេខានៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នាថ្ងៃទី១៥ខែធ្នូឆ្នាំ១៩៨៧ ("អាស៊ាន IGA") ហើយដែលត្រូវបានធ្វើវិសោធនកម្ម ដើម្បីធ្វើឱ្យប្រសើរឡើងថែមទៀតនូវសមាហរណកម្មតំបន់ ក្នុងគោលបំណងសំរេចឱ្យបាននូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ("AEC")

**ជឿជាក់ថា** លំហូរចូលប្រកបដោយចីរភាពនៃវិនិយោគថ្មីៗ និងការធ្វើវិនិយោគឡើងវិញ នឹងជំរុញ ព្រមទាំងធានាបាននូវកិច្ចអភិវឌ្ឍន៍ប្រកបដោយជវភាពនៃសេដ្ឋកិច្ចអាស៊ាន

**ទទួលស្គាល់ថា** បរិស្ថានវិនិយោគប្រកបដោយភាពអនុគ្រោះ នឹងធ្វើឱ្យប្រសើរឡើងនូវលំហូរចូលដោយសេរីនៃមូលធន ទំនិញ និងសេវាកម្ម បច្ចេកវិទ្យា និងធនធានមនុស្ស ព្រមទាំងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមទាំងមូល នៅក្នុងអាស៊ាន និង

**ប្តេជ្ញាថា** ត្រូវពង្រីកកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែខ្លាំងឡើង រវាង និង ក្នុងចំណោមរដ្ឋសមាជិក

**បានឯកភាពគ្នា** ដូចខាងក្រោម :

## ផ្នែក "ក"

## មាត្រា ១

## "គោលបំណង"

គោលបំណងនៃកិច្ចព្រមព្រៀងនេះ គឺដើម្បីបង្កើតឡើងនូវរបបវិនិយោគមួយដែលសេរីនិងបើកចំហរក្នុងអាស៊ាន សំដៅធ្វើឱ្យសំរេចបាននូវគោលដៅចុងក្រោយនៃសមាហរណកម្មសេដ្ឋកិច្ចស្ថិតក្រោមសហគមន៍សេដ្ឋកិច្ចអាស៊ាន អនុលោមទៅតាមផែនការមេនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន តាមរយៈដូចខាងក្រោម :

(ក) ធ្វើសេរីភាវូបនីយកម្មឈានឡើងជាលំដាប់ នៃរបបវិនិយោគរបស់រដ្ឋសមាជិកទាំងអស់

(ខ) ធ្វើប្បញ្ញត្តិកម្មនៃការការពារឱ្យកាន់តែប្រសើរឡើងចំពោះអ្នកវិនិយោគនៃគ្រប់រដ្ឋសមាជិក និងការវិនិយោគរបស់ពួកគេ

(គ) កែលំអតម្លាភាព និងភាពចាំទ់ប្រមាណបាននៃវិធាននានាពាក់ព័ន្ធការវិនិយោគ បទប្បញ្ញត្តិ និងនីតិវិធី ប្រកបដោយភាពអនុគ្រោះ ដើម្បីកំណើនវិនិយោគក្នុងចំណោមរដ្ឋសមាជិក

(ឃ) រួមគ្នាជំរុញតំបន់ឱ្យក្លាយទៅជាតំបន់វិនិយោគដែលមានសមាហរណកម្មជាមួយគ្នា និង

(ង) ធ្វើសហប្រតិបត្តិការដើម្បីបង្កើតបរិយាកាសល្អសំរាប់ការវិនិយោគដោយអ្នកវិនិយោគនៃរដ្ឋសមាជិកមួយ ក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀត

## មាត្រា ២

## "គោលការណ៍ណែនាំ"

កិច្ចព្រមព្រៀងនេះ ត្រូវបង្កើតនូវបរិស្ថានវិនិយោគប្រកបដោយលក្ខណៈសេរី មានភាពងាយស្រួល មានតម្លាភាព និងមានភាពប្រកួតប្រជែងក្នុងអាស៊ាន ដោយភ្ជាប់ជាមួយនូវគោលការណ៍ដូចខាងក្រោម :

(ក) ផ្តល់នូវសេរីភាវូបនីយកម្ម ការការពារ ការជំរុញ និងកិច្ចសំរួលវិនិយោគ

(ខ) ធ្វើសេរីភាវូបនីយកម្មវិនិយោគឈានឡើងជាលំដាប់ ដើម្បីឆ្ពោះទៅសម្រេចឱ្យបាននូវបរិស្ថានវិនិយោគក្នុងតំបន់មួយ ដែលសេរី និងបើកចំហរ

(គ) ផ្តល់ផលប្រយោជន៍ជូនអ្នកវិនិយោគ និងការវិនិយោគរបស់ពួកគេ ដែលមានមូលដ្ឋានទៅក្នុងអាស៊ាន

(ឃ) រក្សា និងផ្តល់ជូននូវប្រព្រឹត្តិកម្មអនុគ្រោះ ក្នុងចំណោមរដ្ឋសមាជិក

(ង) គ្មានការត្រឡប់ក្រោយទេ ចំពោះការប្តេជ្ញា ដែលបានធ្វើក្រោមកិច្ចព្រមព្រៀង AIA និងអាស៊ាន IGA

(ច) ផ្តល់ប្រព្រឹត្តិកម្មពិសេស និងដោយឡែក ព្រមទាំងភាពទន់ភ្លន់ដទៃទៀត ចំពោះរដ្ឋសមាជិកទាំងអស់ ដោយផ្អែកលើកំរិតនៃការអភិវឌ្ឍន៍ និងវេយិតភាពតាមវិស័យ

(ឆ) ប្រព្រឹត្តិកម្មបដិការក្នុងការទទួលបាននូវសម្បទានក្នុងចំណោមរដ្ឋសមាជិក តាមស្ថានភាពសមរម្យ

(ជ) ផ្តល់លទ្ធភាពចំពោះការពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ដើម្បីគ្របដណ្តប់លើវិស័យដទៃទៀតនាពេលអនាគត

## មាត្រា ៣

## "វិសាលភាពនៃការអនុវត្តន៍"

១. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះវិធានការដែលបានអនុម័ត ឬរក្សាទុកដោយរដ្ឋសមាជិកមួយ ទាក់ទងនឹង :

(ក) អ្នកវិនិយោគនៃរដ្ឋសមាជិកណាមួយផ្សេងទៀត និង

(ខ) ការវិនិយោគនៃអ្នកវិនិយោគរបស់រដ្ឋសមាជិកណាមួយផ្សេងទៀត ក្នុងដែនដីរបស់ខ្លួន

២. កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះការវិនិយោគដែលមានស្រាប់ នៅពេលដែលកិច្ចព្រមព្រៀងនេះចូលជាធរមាន ក៏ដូចជាការវិនិយោគដែលបានធ្វើបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន ។

៣. ចំពោះគោលបំណងនៃការធ្វើសេរីភាវូបនីយកម្ម និងផ្នែកតាមមាត្រា ៩ ("ការបំរុងទុក") កិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តចំពោះវិស័យដូចខាងក្រោម :

(ក) កម្មន្តសាល

(ខ) កសិកម្ម

(គ) នេសាទ

(ឃ) រុក្ខា

(ង) រ៉ែ និងអាជីវកម្មថ្ម

(ច) សេវាកម្មបន្ទាប់បន្សំចំពោះ កម្មន្តសាល កសិកម្ម នេសាទ រុក្ខា រ៉ែ និងអាជីវកម្មថ្ម និង

(ឆ) វិស័យដទៃទៀត ដែលអាចត្រូវបានឯកភាពដោយរដ្ឋសមាជិកទាំងអស់

៤. កិច្ចព្រមព្រៀងនេះ មិនត្រូវអនុវត្តចំពោះ :

(ក) វិធានការពន្ធដារណាមួយ លើកលែងតែសំរាប់មាត្រា ១៣ ("ការផ្ទេរ") និងមាត្រា ១៤ ("ការដកហូត និងសំណង")

(ខ) ឧបត្ថម្ភធន ឬជំនួយ ផ្តល់ដោយរដ្ឋសមាជិកមួយ

(គ) លទ្ធកម្មសាធារណៈរបស់រដ្ឋាភិបាល

(ឃ) សេវាកម្ម ដែលផ្គត់ផ្គង់ក្នុងប្រតិបត្តិការរបស់អាជ្ញាធរនៃរដ្ឋាភិបាល ដោយស្ថាប័ន ឬអាជ្ញាធរនៃរដ្ឋសមាជិកមួយ ។ ចំពោះគោលបំណងនៃកិច្ចព្រមព្រៀងនេះ សេវាកម្ម ដែលផ្គត់ផ្គង់ក្នុងប្រតិបត្តិការរបស់អាជ្ញាធរនៃរដ្ឋាភិបាល មានន័យថា សេវាកម្មណាក៏ដោយដែលត្រូវបានផ្គត់ផ្គង់ មិនមែន ជាលក្ខណៈពាណិជ្ជកម្ម ឬក្នុងន័យប្រកួតប្រជែង ជាមួយអ្នកផ្គត់ផ្គង់មួយ ឬច្រើននោះទេ ហើយនិង

(ង) វិធានការ ដែលបានអនុម័ត ឬរក្សាទុកដោយរដ្ឋសមាជិកមួយ ដែលប៉ះពាល់ដល់ពាណិជ្ជកម្មក្នុងសេវាកម្ម ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីសេវាកម្ម ដែលបានចុះហត្ថលេខា នៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៍ នាថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៩៥ ("AFAS") ។

៥. ថ្វីបើមានចែងក្នុងអនុកថាខ័ណ្ឌ ៤(ឃ) ក៏ដោយ សំរាប់គោលបំណងនៃការការពារវិនិយោគទាក់ទងទៅនឹងលំនាំពាណិជ្ជកម្មចំពោះមុខនៃការផ្តត់ផ្គង់សេវាកម្ម មាត្រា ១១ ("ប្រព្រឹត្តិកម្មនៃការវិនិយោគ") មាត្រា ១២ ("សំណងក្នុងករណីមានកលយុគ") មាត្រា ១៣ ("ការផ្ទេរ") មាត្រា ១៤ ("ការដកហូត និង សំណង") និង មាត្រា ១៥ ("ឧបាទេសកម្ម") និងផ្នែក ខ ("វិវាទវិនិយោគរវាងអ្នកវិនិយោគ និង រដ្ឋសមាជិក") ត្រូវអនុវត្ត Mutatis Mutandis ចំពោះវិធានការណា ដែលប៉ះពាល់ដល់ការផ្គត់ផ្គង់សេវាកម្មមួយ ដោយអ្នកផ្គត់ផ្គង់សេវាកម្មនៃរដ្ឋសមាជិកមួយ តាមរយៈវត្តមានពាណិជ្ជកម្មនៅក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀត ប៉ុន្តែលុះណាតែ វិធានការនោះទាក់ទងទៅនឹងការវិនិយោគ និងកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ មិនគិតដល់ថាតើវិស័យសេវាកម្មនោះត្រូវបានដាក់ក្នុងកម្មវិធីនៃការប្តេជ្ញារបស់រដ្ឋសមាជិកដែលបានធ្វើក្រោមកិច្ចព្រមព្រៀង ("AFAS") នោះទេ។

៦. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិ និងកាតព្វកិច្ចនៃរដ្ឋសមាជិក ក្រោមអនុសញ្ញាពន្ធដារណាមួយនោះទេ។ ប្រសិនបើពុំមានសង្គតភាពរវាងកិច្ចព្រមព្រៀងនេះ និងអនុសញ្ញាណាមួយនោះ អនុសញ្ញានោះ ត្រូវធ្វើជាសំអាង។

## មាត្រា ៤
## "និយមន័យ"

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

(ក) **"ដែនវិនិយោគ (Covered Investment)"** មានន័យថា ការវិនិយោគក្នុងដែនដីនៃរដ្ឋសមាជិកមួយរបស់អ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដែលមានស្រាប់ គិតត្រឹមកាលបរិច្ឆេទនៃការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ឬ ដែលបានបង្កើតឡើង បានទិញយក ឬ បានពង្រីកក្រោយពីការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ និងដែលត្រូវបានអនុញ្ញាតដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិ ហើយត្រូវបានអនុម័តជាក់លាក់ជាលាយលក្ខណ៍អក្សរ[១] ពីអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋសមាជិកមួយ តាមការដែលអាចអនុវត្តបាន

[១] សំរាប់គោលបំណងនៃការការពារ នីតិវិធីទាក់ទងនឹងការអនុម័តជាក់លាក់ជាលាយលក្ខណ៍អក្សរ ត្រូវបានកំណត់ជាក់លាក់ក្នុងឧបសម្ព័ន្ធ១ ("ការអនុម័តជាលាយលក្ខណ៍អក្សរ")

(ខ) "**រូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី**" មានន័យថា រូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី ដូចបានកំណត់ដោយមូលនិធិរូបិយវត្ថុអន្តរជាតិ ("IMF") ក្រោមមាត្រានៃកិច្ចព្រមព្រៀងរបស់ IMF និងវិសោធនកម្មនានាដែលមានក្នុងនោះ ។

(គ) "**ការវិនិយោគ**[២]" មានន័យថា ទ្រព្យសម្បត្តិគ្រប់ប្រភេទ ដែលជាកម្មសិទ្ធិ ឬគ្រប់គ្រង ដោយអ្នកវិនិយោគ ដោយរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះទ្រព្យសម្បត្តិដូចខាងក្រោម :

(i) ចលនទ្រព្យ និងអចលនទ្រព្យ និងសិទ្ធិលើទ្រព្យសម្បត្តិដទៃទៀត ដូចជា វត្ថុបញ្ចាំបំណុល ប្រាតិភោគបំណុល (វត្ថុដាក់ធានាបំណុល) ឬប្រាក់សន្យាឱ្យ

(ii) ភាគហ៊ុន ហ៊ុន សញ្ញាប័ណ្ណ និងប័ណ្ណបំណុល និងទំរង់ដទៃទៀតណាមួយនៃការចូលរួមរបស់នីតិបុគ្គល និងសិទ្ធិ ឬ ផលប្រយោជន៍ដែលបានមកពីការចូលរួមនោះ

(iii) កម្មសិទ្ធិបញ្ញា ដែលផ្តល់ឱ្យ ដោយយោងតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋសមាជិកនីមួយៗ

(iv) ការទាមទារសំណងជាប្រាក់ ឬជាការអនុវត្តន៍នៃកិច្ចសន្យា ទាក់ទងនឹងធុរកិច្ច និងមាន តម្លៃហិរញ្ញវត្ថុ[៣]

(v) សិទ្ធិផ្សេងៗក្រោមកិច្ចសន្យា រាប់បញ្ចូលទាំងកិច្ចសន្យាទទួលយកសមិទ្ធិផលហើយស្រេច ការសាងសង់ ការគ្រប់គ្រង ការផលិត ឬកិច្ចសន្យាចែករំលែកប្រាក់ចំណូល និង

(vi) សម្បទានពាណិជ្ជកម្ម ដែលតម្រូវចំពោះដំណើរការសកម្មភាពសេដ្ឋកិច្ច និងមានតម្លៃហិរញ្ញវត្ថុ ដែលបានផ្តល់ឱ្យដោយច្បាប់ ឬ ក្រោមកិច្ចសន្យា រាប់បញ្ចូលទាំងសម្បទាន ដើម្បីស្រាវជ្រាវ ដាំដុះ ការធ្វើនិស្សារណកម្ម ឬ ធ្វើអាជីវកម្មធនធានធម្មជាតិ

---

[២] ទ្រព្យសម្បត្តិ ខ្វះចរិកលក្ខណៈនៃការវិនិយោគ នោះមិនមែនជាការវិនិយោគ ដោយមិនគិតបញ្ចូលនូវទំរង់ដែលវាអាចកើតមាន ។ ចរិកលក្ខណៈ នៃការវិនិយោគ រាប់បញ្ចូលទាំងការប្តេជ្ញាចំពោះមូលធន ការរំពឹងទុកនៃចំណូល ឬចំណេញ ឬក៏ការសន្មត់ពីហានិភ័យ ។

[៣] ដើម្បីឱ្យកាន់តែប្រាកដ ការវិនិយោគ មិនមានន័យថាជាការទាមទារសំណងជាប្រាក់ ដែលកើតឡើងគ្រាន់តែពី :

(ក) កិច្ចសន្យាពាណិជ្ជកម្មសំរាប់លក់ទំនិញ ឬសេវាកម្ម ឬ

(ខ) ការពង្រីកនៃឥណទានទាក់ទងនឹងកិច្ចសន្យាពាណិជ្ជកម្ម

ពាក្យស័ព្ទ "**ការវិនិយោគ**" រាប់បញ្ចូលផងដែរនូវបរិមាណ ដែលទទួលបានពីផលដោយការវិនិយោគ ជាពិសេស ប្រាក់ចំណេញ ការប្រាក់ ចំណេញជាមូលធន ភាគលាភ ប្រាក់បង់ថ្លៃឈ្នួល និងកំរៃសេវា ។ រាល់ការកែទំរង់នៃទ្រព្យសម្បត្តិ ត្រូវបានវិនិយោគ ឬវិនិយោគឡើងវិញ មិនត្រូវឱ្យប៉ះពាល់ដល់ការធ្វើចំណាត់ថ្នាក់នៃការវិនិយោគឡើយ

(ឃ) "**អ្នកវិនិយោគ**" មានន័យថា រូបវ័ន្តបុគ្គលនៃរដ្ឋសមាជិកមួយ ឬនីតិបុគ្គលនៃរដ្ឋសមាជិកមួយ ដែលកំពុងធ្វើ ឬ បានធ្វើការវិនិយោគក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀត

(ង) "**នីតិបុគ្គល**" មានន័យថា នីតិបុគ្គល ដែលបានរៀបចំឡើង ឬ ចាត់ចែងឡើង ក្រោមច្បាប់ ដែលកំពុងអនុវត្តរបស់រដ្ឋសមាជិក មិនថាដើម្បីស្វែងរកចំណេញ ឬក្រៅពីនេះ និងមិនថាជាកម្មសិទ្ធិរបស់ឯកជន ឬកម្មសិទ្ធិរបស់រដ្ឋ រាប់បញ្ចូលទាំងសហគ្រាស សាជីវកម្ម ប្រតិសិទ្ធិកម្ម ភាពជាដៃគូ សម្ព័ន្ធអាជីវកម្ម ឯកកម្មសិទ្ធិ សមាគម ឬអង្គការ

(ច) "**វិធានការ**" មានន័យថា វិធានការណាមួយនៃរដ្ឋសមាជិក ទោះជាក្នុងទំរង់នៃច្បាប់ បទប្បញ្ញត្តិ វិធាន នីតិវិធី សេចក្តីសំរេច និងសកម្មភាពរដ្ឋបាល ឬការអនុវត្តន៍ជាទំលាប់ ដែលបានអនុម័ត ឬរក្សាទុកដោយ :

(i) រដ្ឋាភិបាលឬអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬ ថ្នាក់មូលដ្ឋាន

(ii) ស្ថាប័នមិនមែនរដ្ឋាភិបាល ក្នុងការអនុវត្តន៍នូវសិទ្ធិអំណាច ដែលត្រូវបានប្រតិភូកម្មដោយ រដ្ឋាភិបាលឬអាជ្ញាធរថ្នាក់កណ្តាល ថ្នាក់តំបន់ ឬ ថ្នាក់មូលដ្ឋាន

(ឆ) "**រូបវ័ន្តបុគ្គល**" មានន័យថា រូបវ័ន្តបុគ្គល ដែលមានសញ្ជាតិ ឬការទទួលបាននូវសញ្ជាតិ ឬសិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងរដ្ឋសមាជិក ដោយអនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិរបស់រដ្ឋសមាជិកនោះ ។

(ជ) "**រដ្ឋសមាជិកថ្មីនៃអាស៊ាន**" មានន័យថា ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

(ឈ) "**WTO**" មានន័យថា អង្គការពាណិជ្ជកម្មពិភពលោក និង

(ញ) "**កិច្ចព្រមព្រៀង WTO** " មានន័យថា កិច្ចព្រមព្រៀងម៉ារ៉ាកេស (Marrakesh) ធ្វើនៅទីក្រុងម៉ារ៉ាកេស ប្រទេសម៉ូរ៉ុកកូ នាថ្ងៃទី ១៥ ខែ មេសា ឆ្នាំ១៩៩៤ ដែលអាចត្រូវបានធ្វើវិសោធនកម្ម និងដែលបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ។

## មាត្រា ៥

## "ប្រព្រឹត្តិកម្មជាតិ"

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ឱ្យចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត នូវប្រព្រឹត្តិកម្មនៃការវិនិយោគរបស់ពួកគេ មិនតិចជាងអ្វីដែលខ្លួនបានផ្តល់សំរាប់អ្នកវិនិយោគរបស់ខ្លួនក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការអនុញ្ញាត្តិ ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការធ្វើប្រតិបត្តិការ និងការលក់ ឬការសំរេចរំលាយចោលនូវការវិនិយោគក្នុងដែនដីរបស់ខ្លួន ។

២. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ឱ្យចំពោះការវិនិយោគរបស់អ្នកវិនិយោគ នៃរដ្ឋសមាជិកដទៃទៀត នូវប្រព្រឹត្តិកម្មវិនិយោគមិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យ ចំពោះការវិនិយោគរបស់អ្នកវិនិយោគខ្លួន នៅក្នុងដែនដីរបស់ខ្លួន ក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការអនុញ្ញាត្តិ ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការធ្វើប្រតិបត្តិការ និងការលក់ ឬការសំរេចរំលាយចោលនូវការវិនិយោគ ។

## មាត្រា ៦

## "ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត"[៤]

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ឱ្យចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត នូវប្រព្រឹត្តិកម្មវិនិយោគមិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យ ចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ឬរដ្ឋមិនមែនជាសមាជិក ក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការអនុញ្ញាត្តិ ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការធ្វើប្រតិបត្តិការ និងការលក់ ឬការសំរេចរំលាយចោលនូវការវិនិយោគ ។

---

[៤] **ដើម្បីឱ្យកាន់តែប្រាកដ:**

(ក) មាត្រានេះ មិនត្រូវអនុវត្តចំពោះនីតិវិធីនៃការដោះស្រាយវិវាទរវាងរដ្ឋ និងអ្នកវិនិយោគទេ ដែលវាអាចមាននៅក្នុងកិច្ចព្រមព្រៀងដទៃទៀត ដែលរដ្ឋសមាជិក ជាភាគីនៃកិច្ចព្រមព្រៀងនោះ និង

(ខ) ទាក់ទងនឹងការវិនិយោគនៅក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ប្រព្រឹត្តិកម្មអនុគ្រោះ ដែលត្រូវបានផ្តល់ឱ្យដោយរដ្ឋសមាជិក ចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ឬរដ្ឋមិនមែនជាសមាជិក និងចំពោះការវិនិយោគរបស់គេ ក្រោមកិច្ចព្រមព្រៀងដែលមានស្រាប់ ឬកិច្ចព្រមព្រៀងនាពេលអនាគត ឬការរៀបចំដែលរដ្ឋសមាជិក គឺជាភាគីនៃកិច្ចព្រមព្រៀងនោះ ត្រូវតែត្រូវបានផ្តល់ជូនទៅឱ្យគ្រប់រដ្ឋសមាជិក ផ្អែកតាមមូលដ្ឋានជាតិអនុគ្រោះបំផុត ។

២. រដ្ឋសមាជិកនីមួយៗ ត្រូវយល់ព្រមផ្តល់ឱ្យចំពោះការវិនិយោគរបស់អ្នកវិនិយោគ នៃរដ្ឋសមាជិកដទៃទៀតនូវប្រព្រឹត្តិកម្មវិនិយោគមិនតិចជាងអ្វីដែលខ្លួនបានផ្តល់ឱ្យ ចំពោះការវិនិយោគនៅក្នុងដែនដីរបស់ខ្លួននៃអ្នកវិនិយោគ នៃរដ្ឋសមាជិកដទៃទៀត ឬរដ្ឋមិនមែនសមាជិក ក្នុងកាលៈទេសៈដូចគ្នា ទាក់ទងនឹងការ-អនុញ្ញាត្តិ ការបង្កើត ការទិញយក ការពង្រីក ការគ្រប់គ្រង កិច្ចដំណើរការ ការធ្វើប្រតិបត្តិការ និងការលក់ ឬការសំរេចរំលាយចោលនូវការវិនិយោគ ។

៣. កថាខ័ណ្ឌ ១ និង ២ មិនត្រូវបានបកស្រាយចំពោះកាតព្វកិច្ចនៃរដ្ឋសមាជិក ដើម្បីផ្តល់ឱ្យ ចំពោះអ្នកវិនិយោគ ឬការវិនិយោគនៃរដ្ឋសមាជិកដទៃទៀត នូវផលប្រយោជន៍នៃប្រព្រឹត្តិកម្ម ការអនុគ្រោះ ឬបុព្វសិទ្ធិ ដែលកើតចេញពី :

(ក) ការរៀបចំអនុតំបន់រវាង និងក្នុងចំណោមរដ្ឋសមាជិក[៥] ឬ

(ខ) កិច្ចព្រមព្រៀងមានស្រាប់ ដែលត្រូវបានជូនដំណឹងដោយរដ្ឋសមាជិក ជូនក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន យោងតាមមាត្រា ៨(៣) នៃកិច្ចព្រមព្រៀង[៦] AIA ។

## មាត្រា ៧

## "ការហាមឃាត់ការតម្រូវឱ្យបំពេញកាតព្វកិច្ច"

១. បញ្ញត្តិនៃកិច្ចព្រមព្រៀងស្តីពីវិធានការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម ក្នុងឧបសម្ព័ន្ធ ១ ក ចំពោះកិច្ចព្រមព្រៀង WTO (TRIMs) ដែលមិនត្រូវបានចែងជាក់លាក់ ឬកែប្រែដោយកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្ត mutatis mutandis ចំពោះកិច្ចព្រមព្រៀងនេះ ។

២. រដ្ឋសមាជិកទាំងអស់ ត្រូវអនុវត្តនូវការវាយតម្លៃរួមគ្នាស្តីពីការតម្រូវឱ្យបំពេញកាតព្វកិច្ច មិនឱ្យហួសពី ២ (ពីរ) ឆ្នាំ ចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃកិច្ចព្រមព្រៀងនេះ ។ គោលបំណងនៃការវាយតម្លៃនេះ ត្រូវ

---

[៥] ដើម្បីឱ្យកាន់តែប្រាកដ ការរៀបចំអនុតំបន់រវាង និងក្នុងចំណោមរដ្ឋសមាជិក ត្រូវរាប់បញ្ចូល ប៉ុន្តែមិនកំណត់ចំពោះមហាអនុតំបន់មេគង្គ (GMS) សហប្រតិបត្តិការអភិវឌ្ឍន៍អាងទន្លេមេគង្គ-អាស៊ាន (AMBDC) តំបន់ត្រីកោណលូតលាស់ ឥណ្ឌូនេស៊ី-ម៉ាឡេស៊ី-ថៃឡង់ដ៏ (IMT-GT) តំបន់ត្រីកោណលូតលាស់ ឥណ្ឌូនេស៊ី-ម៉ាឡេស៊ី-សិង្ហបុរី (IMS-GT) តំបន់លូតលាស់អាស៊ានខាងកើត ព្រុយណេ-ឥណ្ឌូនេស៊ី-ម៉ាឡេស៊ី-ហ្វីលីពីន (BIMP-EAGA) ។

[៦] អនុកថាខ័ណ្ឌនេះ យោងដល់សន្ធិសញ្ញានៃសន្ថិមិត្ត និងទំនាក់ទំនងសេដ្ឋកិច្ចរវាងព្រះរាជាណាចក្រថៃឡង់ដ៏ និងសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខានៅទីក្រុងបាងកក ប្រទេសថៃឡង់ដ៏ នាថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៦៦ ។

រាប់បញ្ចូលទាំងការពិនិត្យសើរើចំពោះការតម្រូវឱ្យបំពេញកាតព្វកិច្ចដែលមានស្រាប់ និងពិនិត្យអំពីសេចក្តីត្រូវការសំរាប់ការប្តេជ្ញាបន្ថែមក្រោមមាត្រានេះ ។

៣. រដ្ឋសមាជិកអាស៊ានដែលមិនមែនជាសមាជិក WTO ត្រូវអនុវត្តតាមបញ្ញត្តិនៃ WTO ដោយអនុលោមតាមការប្តេជ្ញានៃការចូលជាសមាជិក WTO របស់ខ្លួន ។

## មាត្រា ៨

## "គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល"

១. រដ្ឋសមាជិកមួយ មិនតម្រូវឱ្យនីតិបុគ្គលនៃរដ្ឋសមាជិកនោះ តែងតាំងក្នុងតំណែងគណៈគ្រប់គ្រងជាន់ខ្ពស់នូវរូបវ័ន្តបុគ្គលនៃសញ្ជាតិណាមួយនោះទេ ។

២. រដ្ឋសមាជិកមួយ អាចតម្រូវឱ្យក្រុមប្រឹក្សាភិបាលភាគច្រើនរបស់នីតិបុគ្គលនៃរដ្ឋសមាជិកនោះ ជាសញ្ជាតិពិសេសមួយ ឬអ្នកស្នាក់នៅក្នុងដែនដីនៃរដ្ឋសមាជិក ប្រសិនបើតម្រូវការនោះ មិនប៉ះពាល់ដោយជាក់ស្តែងដល់សមត្ថភាពនៃអ្នកវិនិយោគក្នុងការអនុវត្តនីការគ្រប់គ្រងលើការវិនិយោគរបស់ខ្លួនគេទេនោះ ។

## មាត្រា ៩

## "ការបំរុងទុក"

១. មាត្រា ៥ ("ប្រព្រឹត្តិកម្មជាតិ") និង ៨ ("គណៈគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល") មិនត្រូវអនុវត្តចំពោះ :

(ក) វិធានការណាមួយដែលមានស្រាប់ដែលត្រូវបានរក្សាទុកដោយរដ្ឋសមាជិកមួយ ក្នុងកំរិត :

(i) រដ្ឋាភិបាលថ្នាក់កណ្តាល ដូចមានចែងដោយរដ្ឋសមាជិកនោះ នៅក្នុងបញ្ជីបំរុងទុករបស់ខ្លួន នៅក្នុងតារាងកាតព្វកិច្ចដែលយោងដល់កថាខ័ណ្ឌ ២

(ii) រដ្ឋាភិបាលថ្នាក់តំបន់ ដូចមានចែងដោយរដ្ឋសមាជិកនោះ នៅក្នុងបញ្ជីបំរុងទុករបស់ខ្លួន នៅក្នុងតារាងកាតព្វកិច្ចដែលយោងដល់កថាខ័ណ្ឌ ២ និង

(iii) រដ្ឋាភិបាលថ្នាក់មូលដ្ឋាន

(ខ) ការបន្ត ឬការពន្យារពេលជាកំណត់ នៃការបំរុងទុក យោងតាមអនុកថាខ័ណ្ឌ (ក)

២. រដ្ឋសមាជិកនីមួយៗ ត្រូវផ្ញើបញ្ជីបំរុងទុករបស់ខ្លួនទៅជូនលេខាធិការដ្ឋានអាស៊ាន សំរាប់សុំការឯកភាពពីក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ក្នុងរយៈពេល ៦ខែ បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។ បញ្ជីនេះ ត្រូវបង្កើតជាតារាងកាតព្វកិច្ច ចំពោះកិច្ចព្រមព្រៀងនេះ ។

៣. វិសោធនកម្ម ឬការកែសម្រួលណាមួយ ចំពោះការបំរុងទុកណាមួយ ដែលមាននៅក្នុងតារាងកាតព្វកិច្ច យោងតាមកថាខ័ណ្ឌ ២ ត្រូវអនុលោមតាម មាត្រា ១០ ( "ការកែសម្រួលនៃការប្តេជ្ញា" ) ។

៤. រដ្ឋសមាជិកនីមួយៗ ត្រូវកាត់បន្ថយ ឬលុបបំបាត់នូវការបំរុងទុក ដែលបានចង្អុលបង្ហាញនៅក្នុងតារាងកាតព្វកិច្ច ដោយអនុលោមតាមដំណាក់កាលទាំងបីនៃតារាងកាតព្វកិច្ចជាយុទ្ធសាស្ត្ររបស់ផែនការមេនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងមាត្រា ៤៦ ( "វិសោធនកម្ម" ) ។

៥. មាត្រា ៥ ( "ប្រព្រឹត្តិកម្មជាតិ" ) និង ៦ ( ប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត" ) មិនត្រូវអនុវត្តចំពោះវិធានការណាមួយ ដែលត្រូវបានគ្របដណ្តប់ដោយការលើកលែងចំពោះ ឬការដកហូតពីកាតព្វកិច្ច ក្រោមមាត្រា ៣ និង៤ នៃកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពទាក់ទងនឹងពាណិជ្ជកម្ម នៃកម្មសិទ្ធិបញ្ញា ( កិច្ចព្រមព្រៀង TRIPS ) ក្នុងឧបសម្ព័ន្ធ ១ C នៃកិច្ចព្រមព្រៀង WTO ដែលអាចត្រូវបានធ្វើវិសោធនកម្ម ដូចបានផ្តល់ជូនជាក់លាក់នៅក្នុងមាត្រាទាំងនោះ និងក្នុងមាត្រា ៥ នៃកិច្ចព្រមព្រៀង TRIPS ។

## មាត្រា ១០
## "ការកែសម្រួលនៃការប្តេជ្ញា"

១. រដ្ឋសមាជិកមួយ អាចអនុម័តនូវវិធានការណាមួយ ឬកែសម្រួលការបំរុងទុករបស់ខ្លួន ក្នុងរយៈពេល ១២ ( ដប់ពីរ ) ខែ បន្ទាប់ពីថ្ងៃដាក់បញ្ជីបំរុងទុករបស់រដ្ឋសមាជិកនីមួយៗ ដែលបានធ្វើនៅក្នុងតារាងកាតព្វកិច្ច ក្រោមមាត្រា ៩ ( "ការបំរុងទុក" ) សំរាប់ការអនុវត្តនាពេលអនាគតចំពោះអ្នកវិនិយោគ នៃរដ្ឋសមាជិកដទៃទៀត និងការវិនិយោគរបស់ពួកគេ ប្រសិនបើវិធានការ ឬការកែសម្រួលទាំងនោះ នឹងមិនប៉ះពាល់ធ្ងន់ធ្ងរចំពោះអ្នកវិនិយោគ និងការវិនិយោគដែលមានស្រាប់ណាមួយនោះទេ ។

២. បន្ទាប់ពីផុតសុពលភាពដែលមានចែងក្នុងកថាខ័ណ្ឌ ១ រដ្ឋសមាជិកមួយ អាចអនុម័តនូវវិធានការណាមួយ ឬកែសម្រួល ឬដកចេញនូវការប្តេជ្ញា និងការបំរុងទុក ដោយត្រូវចរចាឱ្យមានការឯកភាពជាមួយនឹងរដ្ឋសមាជិកដទៃទៀត ចំពោះអ្វីដែលខ្លួនបានធ្វើការប្តេជ្ញា ក្រោមកិច្ចព្រមព្រៀងនេះ ប្រសិនបើ វិធានការ

ការកែសម្រួល ឬការដកចេញនោះ នឹងមិនប៉ះពាល់ធ្ងន់ធ្ងរចំពោះអ្នកវិនិយោគ ឬការវិនិយោគដែលមានស្រាប់ណាមួយនោះទេ[៧] ។

៣. ក្នុងកិច្ចចរចា និងការយល់ព្រមណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌ ២ ដែលអាចរាប់បញ្ចូលនូវប្បញ្ញត្តិសំរាប់ការធ្វើនិយ័តកម្មសង ទាក់ទងនឹងវិស័យដទៃទៀត រដ្ឋសមាជិកពាក់ព័ន្ធ ត្រូវរក្សាទុកនូវកំរិតទូទៅនៃការប្តេជ្ញាដែលមានសារប្រយោជន៍ជាបដិការនិងទៅវិញទៅមក និងការបំរុងទុក មិនតិចជាងអ្វី ដែលបានផ្តល់ឱ្យទៅអ្នកវិនិយោគ និងការវិនិយោគ ដូចមានក្នុងកិច្ចព្រមព្រៀងនេះ មុនពេលការចរចានិងការយល់ព្រមនោះទេ ។

៤. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ និង ២ ក៏ដោយ ក្រោមវិធានការណាមួយដែលត្រូវបានអនុម័ត ដូចមានចែងក្នុងមាត្រានេះបន្ទាប់ពីកិច្ចព្រមព្រៀងនេះចូលជាធរមាន រដ្ឋសមាជិកមួយ មិនត្រូវទាមទារឱ្យអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដោយមូលហេតុនៃសញ្ជាតិរបស់អ្នកវិនិយោគនោះ ដើម្បីលក់ ឬសំរេចចិត្តលះបង់ការវិនិយោគ ដែលមានស្រាប់បានទេ ខណៈពេលដែលវិធានការនោះ ចូលជាធរមាន លើកលែងមានការបញ្ជាក់ក្នុងការអនុម័តជាបឋមដោយអាជ្ញាធរពាក់ព័ន្ធ ។

## មាត្រា ១១
## "ប្រព្រឹត្តិកម្មនៃការវិនិយោគ"

១. រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ឱ្យនូវប្រព្រឹត្តិកម្ម សមភាពនិងយុត្តិធម៌ ព្រមទាំងការការពារ និងសុវត្ថិភាពពេញលេញ ចំពោះដែនវិនិយោគរបស់អ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ។

២. ដើម្បីឱ្យកាន់តែច្បាស់ :

(ក) ប្រព្រឹត្តិកម្មសមភាព និងយុត្តិធម៌ តម្រូវឱ្យរដ្ឋសមាជិកនីមួយៗ មិនត្រូវបដិសេធនូវយុត្តិធម៌ក្នុងកិច្ចដំណើរការតាមផ្លូវច្បាប់ ឬតាមផ្លូវរដ្ឋបាលណាមួយឡើយ ដោយអនុលោមតាមគោលការណ៍នៃដំណើរការត្រឹមត្រូវតាមច្បាប់ និង

(ខ) ការការពារ និងសុវត្ថិភាពពេញលេញ តម្រូវឱ្យរដ្ឋសមាជិកនីមួយៗ ចាត់វិធានការចាំបាច់ដែលសមស្រប ដើម្បីធានាឱ្យបាននូវការការពារ និងសុវត្ថិភាពនៃដែនវិនិយោគ ។

---

[៧] ដើម្បីចៀសវាងការមន្ទិលសង្ស័យ រដ្ឋសមាជិក មិនត្រូវអនុម័តវិធានការណាមួយ ឬកែសម្រួលការបំរុងទុកណាមួយក្រោមតារាងកាតព្វកិច្ច ក្នុងរយៈពេល ៦ខែ បន្ទាប់ពីផុតសុពលភាពនៃរយៈពេលដែលបានកំណត់នៅក្នុងកថាខ័ណ្ឌ ១ ។

៣. សេចក្តីសំរេចចិត្តណាមួយ ដែលមានចរិតជាការបំពានចំពោះបញ្ញត្តិដទៃទៀតនៃកិច្ចព្រមព្រៀងនេះ ឬ កិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀតនោះ ពុំមានន័យថា ជាការបំពាននៃមាត្រានេះឡើយ ។

## មាត្រា ១២

## "សំណងក្នុងករណីមានកលយុគ"

រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់នូវប្រព្រឹត្តិកម្មមិនរើសអើងទាក់ទងនឹង បដិទាន សំណង ឬ ដំណោះស្រាយជាតម្លៃដទៃទៀត ចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀតពាក់ព័ន្ធនឹងដែនវិនិយោគរបស់ពួកគេ ដែលទទួលរងនូវការខូចខាតក្នុងដែនដីនៃរដ្ឋសមាជិកនោះ ដោយសារ ជំលោះប្រដាប់អាវុធ ឬ កលយុគស៊ីវិល ឬការដាក់រដ្ឋឱ្យស្ថិតក្នុងភាពអាសន្ន ។

## មាត្រា ១៣

## "ការផ្ទេរ"

១. រដ្ឋសមាជិកនីមួយៗ ត្រូវអនុញ្ញាតិឱ្យធ្វើការផ្ទេរចូល ឬផ្ទេរចេញ នៅក្នុងដែនដីរបស់ខ្លួន ដោយសេរី និង ដោយគ្មានការយឺតយ៉ាវ ពាក់ព័ន្ធនឹងដែនវិនិយោគ ។ ការផ្ទេរទាំងនោះ រាប់បញ្ចូល :

(ក) វិភាគទានចំពោះមូលធន រាប់បញ្ចូលទាំងវិភាគទានជាបឋម

(ខ) ប្រាក់ចំណេញ ចំណេញជាមូលធន ភាគលាភ កំរៃសួយសារ កំរៃអាជ្ញាប័ណ្ណ ជំនួយបច្ចេកទេស និងកំរៃនៃការគ្រប់គ្រង និងបច្ចេកទេស ការប្រាក់ និងប្រាក់ចំណូលដទៃទៀត ដែលកើតពីដែនវិនិយោគណាមួយ

(គ) ផលដែលទទួលបានពីការលក់សរុប ឬលក់មួយផ្នែក ឬការរំលាយក្រុមហ៊ុន នៃដែនវិនិយោគណាមួយ

(ឃ) ការទូទាត់ ដែលបានធ្វើក្រោមកិច្ចសន្យាមួយ រាប់បញ្ចូលទាំង កិច្ចព្រមព្រៀងកម្ចីមួយ

(ង) ការទូទាត់ ដោយអនុលោមតាមមាត្រា ១២ (សំណងក្នុងករណីមានកលយុគ) និង ១៤ (ការដកហូត និងសំណង)

(ច) ការទូទាត់កើតឡើងពីដំណោះស្រាយវិវាទដោយមធ្យោបាយណាមួយ រាប់បញ្ចូលទាំងការវិនិច្ឆ័យ មជ្ឈត្តវិនិច្ឆ័យ ឬកិច្ចព្រមព្រៀងនៃរដ្ឋសមាជិកចំពោះវិវាទ និង

(ឆ) ចំណូល និងប្រាក់បៀវត្សដទៃទៀត នៃបុគ្គលិកបំរើការងារទាក់ទងនឹងដែនវិនិយោគនៅក្នុងដែនដីរបស់ខ្លួន

២. រដ្ឋសមាជិកនីមួយៗ ត្រូវអនុញ្ញាតិឱ្យធ្វើការផ្ទេរទាក់ទងនឹងដែនវិនិយោគនូវរូបិយប័ណ្ណអាចប្រើប្រាស់ដោយសេរី ក្នុងអត្រាប្តូរប្រាក់តាមអត្រាទីផ្សារក្នុងពេលនៃការផ្ទេរនោះ ។

៣. ថ្វីបើមានចែងក្នុងកថាខ័ណ្ឌ ១ និង ២ ក៏ដោយ រដ្ឋសមាជិកមួយ អាចការពារ ឬពន្យាពេលនៃការផ្ទេរមួយ តាមរយៈច្បាប់ និងបទប្បញ្ញត្តិរបស់ខ្លួន ដោយសុចរិត គ្មានរើសអើង និងសមធម៌ ទាក់ទងនឹង :

(ក) ការខ្ស័យធន ភាពមិនអាចសងបំណុលបាន ឬការការពារនៃសិទ្ធិរបស់ឥណទានករ

(ខ) ការផ្សាយ ការធ្វើពាណិជ្ជកម្ម ឬការចែកចាយមូលប័ត្រ អាជីវកម្មមូលប័ត្រ ភាគហ៊ុនអនាគត សិទ្ធិទិញ ឬ លក់ភាគហ៊ុនអនាគត និងការទិញ-លក់ភាគហ៊ុននៃភាគហ៊ុនអនាគត

(គ) បទល្មើសឧក្រិដ្ឋកម្ម ឬបទល្មើសព្រហ្មទណ្ឌ និងប្រាក់ដែលទទួលបានពីរឿងក្តីនៃបទឧក្រិដ្ឋកម្ម

(ឃ) របាយការណ៍ហិរញ្ញវត្ថុ ឬការរក្សាទុកនូវកំណត់ត្រានៃការផ្ទេរពេលចាំបាច់ដើម្បីជួយដល់ការអនុវត្តច្បាប់ ឬអាជ្ញាធរនិយ័តកម្មហិរញ្ញវត្ថុ

(ង) ធានានូវការអនុវត្តនីតាមដីការ ឬសាលក្រមក្នុងកិច្ចដំណើរការក្តីតាមផ្លូវតុលាការ ឬតាមផ្លូវរដ្ឋបាល

(ច) ពន្ធដារ

(ឆ) សុវត្ថិភាពសង្គម ការចូលនិវត្តន៍សាធារណៈ ឬគំរោងសន្សំចាំបាច់

(ជ) ការកាត់ចេញនូវសិទ្ធិជានិយោជិត និង

(ឈ) ការតម្រូវចំពោះការចុះបញ្ជី និងការធ្វើតាមបែបបទដទៃទៀត ដែលកំណត់ដោយធនាគារកណ្តាល និងអាជ្ញាធរពាក់ព័ន្ធដទៃទៀតនៃរដ្ឋសមាជិកមួយ

៤. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវប៉ះពាល់ដល់សិទ្ធិនិងកាតព្វកិច្ចនៃរដ្ឋសមាជិកក្នុងនាមជាសមាជិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ក្រោមមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ រាប់បញ្ចូលទាំងការប្រើប្រាស់សកម្មភាពប្តូរប្រាក់ ដែលអនុលោមតាមមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុ ក្នុងលក្ខខណ្ឌថា រដ្ឋសមាជិកមួយ នឹងមិនដាក់ការកំហិតកំណត់លើកិច្ចការជំនួញមូលធនណាមួយ ដែលគ្មានសង្គតភាពជាមួយការប្តេជ្ញាជាក់លាក់ក្រោមកិច្ចព្រមព្រៀងនេះ ទាក់ទងនឹងកិច្ចការជំនួញនោះ លើកលែងតែ :

(ក) តាមសំណើររបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

(ខ) ក្រោមមាត្រា ១៦ (វិធានការដើម្បីការពារសុវត្ថិភាពជញ្ជីងទូទាត់) ឬ

(គ) ក្នុងកាលៈទេសៈខុសប្រក្រតី ចលនានៃមូលធនដែលបណ្តាលឱ្យ ឬ គំរាមឱ្យមានភាពវឹកវរធ្ងន់ធ្ងរផ្នែកសេដ្ឋកិច្ច ឬ ហិរញ្ញវត្ថុ នៅក្នុងរដ្ឋសមាជិកពាក់ព័ន្ធ

វិធានការ ដែលត្រូវអនុវត្ត ដោយអនុលោមតាមអនុកថាខ័ណ្ឌ៤(គ)[៨] :

(ក) ត្រូវមានសង្គតភាពជាមួយមាត្រានានានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

(ខ) មិនត្រូវឱ្យលើសពីការចាំបាច់ ទាក់ទងនឹងកាលៈទេសៈ ដែលត្រូវបានពិពណ៌នាក្នុង អនុកថាខ័ណ្ឌ ៤ (គ)

(គ) ត្រូវមានជាបណ្តោះអាសន្ន នឹងត្រូវលុបចេញពីបញ្ជីនូវលក្ខខណ្ឌ ដែលលែងមាន ការធ្វើយុត្តិកម្មក្នុងស្ថាប័ន ឬការថែរក្សាទុករបស់វិធានការនោះ

(ឃ) ត្រូវជូនដំណឹងជាបន្ទាន់ទៅគ្រប់ប្រទេសជាសមាជិកដទៃទៀត

(ង) ត្រូវបានអនុវត្តដូចគ្នាដោយរដ្ឋណាមួយនៃរដ្ឋសមាជិកដទៃទៀតនូវប្រព្រឹត្តិកម្មមានភាពអនុគ្រោះមិនតិចជាង រដ្ឋសមាជិកណាមួយទៀត ឬរដ្ឋមិនមែនសមាជិក

(ច) ត្រូវអនុវត្តចំពោះគោលការណ៍ប្រព្រឹត្តិកម្មជាតិ និង

(ឆ) ត្រូវចៀសវាងការខូចខាតមិនចាំបាច់ ចំពោះអ្នកវិនិយោគ និងដែនវិនិយោគ ព្រមទាំង ផលប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃរដ្ឋសមាជិកដទៃទៀត ។

## មាត្រា ១៤

## "ការដកហូត និងសំណង[៩]"

១. រដ្ឋសមាជិកមួយ មិនត្រូវដកហូត ឬធ្វើជាតូបនីយកម្មនូវដែនវិនិយោគមួយ ទោះបី ដោយផ្ទាល់ ឬ តាមរយៈវិធានការប្រហាក់ប្រហែលនឹងការដកហូត ឬធ្វើជាតូបនីយកម្ម ("ការដកហូត")[១០] ក្តី លើកលែងតែ :

(ក) សំរាប់គោលបំណងសាធារណៈ

(ខ) លើមូលដ្ឋានមិនរើសអើង

(គ) មានការទូទាត់សំណងភ្លាមៗ សមរម្យ និងមានប្រសិទ្ធិភាព

---

[៨] **ដើម្បីឱ្យកាន់តែប្រាកដ** វិធានការណាមួយ ដែលត្រូវលើកយកមកអនុវត្ត ដើម្បីធានាស្ថេរភាពនៃអត្រាប្តូរប្រាក់ រាប់បញ្ចូលដើម្បីទប់ស្កាត់ការកេងប្រយោជន៍ពីលំហូរមូលធន មិនត្រូវអនុម័ត ឬរក្សាទុកសំរាប់គោលបំណងនៃការ ការពារវិស័យជាពិសេសណាមួយនោះទេ ។

[៩] មាត្រានេះ ត្រូវអានភ្ជាប់ជាមួយឧបសម្ព័ន្ធ២ (ការដកហូត និងសំណង)

[១០] ដើម្បីចៀសវាងការមន្ទិលសង្ស័យ វិធានការណាមួយនៃការដកហូតទាក់ទងនឹងដីធ្លី ត្រូវតែបានកំណត់ឱ្យបានច្បាស់ ក្នុងច្បាប់និងបទប្បញ្ញត្តិក្នុងស្រុកដែលមានជាធរមាន ហើយការធ្វើវិសោធនកម្មណាមួយចំពោះច្បាប់ និងបទប្បញ្ញត្តិនោះ ត្រូវធ្វើឡើងក្នុងគោលបំណងឱ្យមានការទូទាត់សំណងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិដែលបានរៀបរាប់ខាងលើ ។

(ឃ) អនុលោមតាមដំណើរការនៃច្បាប់

២. សំណង ដែលយោងដល់អនុកថាខ័ណ្ឌ ១(គ) ត្រូវ :

(ក) ទូទាត់ដោយគ្មានការពន្យារពេល[១១]

(ខ) សមមូលជាមួយតម្លៃទីផ្សារសមរម្យ នៃការវិនិយោគដែលបានដកហូតមុន ឬ ក្នុងពេលដែលការដកហូតត្រូវបានប្រកាសជាសាធារណៈ ឬ ពេលដែលការដកហូតបានកើតឡើង ដោយជ្រើសរើសមួយណា ដែលអាចអនុវត្តបាន

(គ) មិនឆ្លុះបញ្ចាំងពីការប្រែប្រួលក្នុងតម្លៃ ដោយសារបំណងនៃការដកហូតនេះ ត្រូវបានដឹងជាមុន និង

(ឃ) ទទួលបាន និងផ្ទេរបានដោយសេរី ដោយអនុលោមតាមមាត្រា ១៣ ("ការផ្ទេរ") រវាងដែនដីនៃរដ្ឋសមាជិកទាំងអស់

៣. ក្នុងករណីពន្យាពេល សំណងត្រូវរាប់បញ្ចូលទាំងការប្រាក់សមស្រប ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិនៃរដ្ឋសមាជិក ដែលធ្វើការដកហូត ។ សំណងរាប់បញ្ចូលទាំងការប្រាក់ដែលកើតឡើងពីការពន្យាពេលសង ត្រូវទូទាត់ឬមួយជារូបិយប័ណ្ណដែលការវិនិយោគត្រូវបានធ្វើពីដំបូង ឬ ជារូបិយប័ណ្ណ ដែលអាចប្រើបានដោយសេរី ប្រសិនបើ មានសំណើពីអ្នកវិនិយោគ ។

៤. ប្រសិនបើអ្នកវិនិយោគ ស្នើការទូទាត់ជារូបិយប័ណ្ណដែលអាចប្រើប្រាស់បានដោយសេរី សំណងត្រូវយោងដល់អនុកថាខ័ណ្ឌ ១(គ) រាប់បញ្ចូលទាំងការប្រាក់ដែលទទួលបានពីការពន្យាពេលសង ត្រូវប្តូរទៅជារូបិយប័ណ្ណនៃការទូទាត់ក្នុងអត្រាប្តូរប្រាក់នៃទីផ្សារ នៅថ្ងៃទូទាត់សំណងនោះតែម្តង ។

៥. មាត្រានេះ មិនអនុវត្តចំពោះការចេញអាជ្ញាប័ណ្ណចាំបាច់ដែលត្រូវផ្តល់ជូនទាក់ទងនឹងកម្មសិទ្ធិបញ្ញាទេ ដោយអនុលោមទៅតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ។

## មាត្រា ១៥

## "ឧបាទេសកម្ម"

១. ប្រសិនបើ រដ្ឋសមាជិកមួយ ឬភ្នាក់ងារមួយនៃរដ្ឋសមាជិកមួយ ធ្វើការទូទាត់ចំពោះវិនិយោគនៃរដ្ឋសមាជិកនោះ ក្រោមការធានាមួយ កិច្ចសន្យានៃធានារ៉ាប់រង ឬក្នុងទំរង់ផ្សេងទៀតនៃប្រាក់សំណង

[១១] គ្រប់រដ្ឋសមាជិក ត្រូវយល់ថាអាចមានដំណើរការច្បាប់ និងរដ្ឋបាល ដែលត្រូវការឱ្យមានការអង្កេត មុនពេលការ ទូទាត់ត្រូវបានធ្វើឡើង

ដែលបានផ្តល់ឱ្យសំរាប់ហានិភ័យមិនមែនពាណិជ្ជកម្ម ទាក់ទងនឹងការវិនិយោគមួយ រដ្ឋសមាជិកដទៃទៀត ត្រូវទទួលស្គាល់នូវឧបាទេសកម្ម ឬការផ្ទេរនៃសិទ្ធិ ឬសិទ្ធិទទួល ទាក់ទងនឹងការវិនិយោគនោះ ។ សិទ្ធិនៃឧបាទេសកម្ម ឬការផ្ទេរ ឬបណ្តឹងទាមទារ មិនត្រូវធំជាងសិទ្ធិដើម ឬបណ្តឹងទាមទារនៃអ្នកវិនិយោគទេ ។ ប៉ុន្តែ នេះមិនមានន័យថា ជាការទទួលស្គាល់នៃរដ្ឋសមាជិកដទៃទៀត ចំពោះគុណសម្បត្តិនៃករណីណាមួយ ឬ ចំនួននៃការទាមទារណាមួយ ដែលកើតឡើងពីបណ្តឹងនោះទេ ។

២. រដ្ឋសមាជិកមួយ ឬភ្នាក់ងារនៃរដ្ឋសមាជិកមួយ ដែលបានធ្វើការទូទាត់ឱ្យអ្នកវិនិយោគនៃរដ្ឋសមាជិកនោះ ហើយបានកាន់កាប់សិទ្ធិ និងការទាមទាររបស់អ្នកវិនិយោគ អ្នកវិនិយោគនោះ មិនត្រូវអនុវត្តសិទ្ធិ និងការទាមទារទាំងនោះ ប្រឆាំងនឹងរដ្ឋសមាជិកដទៃទៀតឡើយ លើកលែងតែ បានទទួលសិទ្ធិដើម្បីដើរតួក្នុងនាមរដ្ឋសមាជិក ឬភ្នាក់ងារនៃរដ្ឋសមាជិកដែលកំពុងធ្វើការទូទាត់នោះ ។

៣. ក្នុងការអនុវត្តនីជាក់ស្តែងនូវសិទ្ធិដែលបានធ្វើឧបាទេសកម្ម ឬការទាមទារ រដ្ឋសមាជិកមួយ ឬភ្នាក់ងារនៃរដ្ឋសមាជិកដែលអនុវត្តសិទ្ធិ ឬការទាមទារនោះ ត្រូវប្រកាសនូវវិសាលភាពនៃការរៀបចំការទាមទារជាមួយអ្នកវិនិយោគរបស់ខ្លួន ឱ្យរដ្ឋសមាជិកដទៃទៀតជ្រាបជាដំណឹងផង ។

## មាត្រា ១៦

## (វិធានការដើម្បីការពារសុវត្ថិភាពជញ្ជីងទូទាត់)

១. ក្នុងព្រឹត្តិការណ៍ដែលជញ្ជីងទូទាត់មានបញ្ហាធ្ងន់ធ្ងរ និងបញ្ហាលំបាក ឬគ្រោះគំរាមកំហែងផ្នែកហិរញ្ញវត្ថុខាងក្រៅ រដ្ឋសមាជិកមួយ អាចអនុម័ត ឬរក្សាទុកនូវការកំហិតកំណត់លើការទូទាត់ ឬការផ្ទេរ ដែលទាក់ទងនឹងការវិនិយោគ ។ វាត្រូវបានទទួលស្គាល់ថា ការគាបសង្កត់ជាពិសេសលើជញ្ជីងទូទាត់នៃរដ្ឋសមាជិកមួយនៅក្នុងដំណើរការនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច អាចជាប្រការចាំបាច់ត្រូវប្រើប្រាស់ក្នុងការកំណត់លក្ខខណ្ឌ ដើម្បីធានាបាននូវការថែរក្សាកំរិតមួយនៃការបំរុងទុកហិរញ្ញវត្ថុសមស្រប សំរាប់ការអនុវត្តន៍នៃកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ខ្លួន ។

២. ការកំណត់លក្ខខណ្ឌដែលយោងដល់កថាខ័ណ្ឌ ១ :

(ក) ត្រូវមានសង្គតភាពជាមួយមាត្រានៃកិច្ចព្រមព្រៀងរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ

(ខ) ត្រូវចៀសវាងការខូចខាតមិនចាំបាច់ចំពោះផលប្រយោជន៍ពាណិជ្ជកម្ម សេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃរដ្ឋសមាជិកដទៃទៀត

(គ) មិនត្រូវលើសពីការចាំបាច់ដែលត្រូវសម្របសម្រួលជាមួយកាលៈទេសៈ ដែលបានរៀបរាប់ក្នុងកថាខ័ណ្ឌ១ ទេ

(ឃ) ត្រូវមានលក្ខណៈបណ្តោះអាសន្ន និងត្រូវលុបចោលជាលំដាប់នៅពេលស្ថានភាពបញ្ជាក់ក្នុងកថាខ័ណ្ឌ ១ មានកែលំអ

(ង) ត្រូវបានអនុវត្តនូវការកំហិតកំណត់នេះដោយរដ្ឋសមាជិកដទៃណាមួយទៀត ត្រូវបានទទួលប្រព្រឹត្តិកម្មមិនតិចជាងរដ្ឋសមាជិកដទៃណាមួយទៀត ឬរដ្ឋមិនមែនសមាជិកនោះឡើយ

៣. ការកំណត់លក្ខខណ្ឌណាមួយ ដែលបានអនុម័ត ឬ រក្សាទុកក្រោមកថាខ័ណ្ឌ ១ ឬការប្រែប្រួលណាមួយ ត្រូវជូនដំណឹងភ្លាមទៅរដ្ឋសមាជិកដទៃទៀត ។

៤. ប្រសិនបើ វាមិនជាន់គ្នាជាមួយដំណើរការស្ថិតក្រោមអង្គការពាណិជ្ជកម្មពិភពលោក មូលនិធិរូបិយវត្ថុអន្តរជាតិ ឬដំណើរការប្រហាក់ប្រហែលគ្នាដទៃទៀតទេនោះ រដ្ឋសមាជិក ដែលកំពុងកំណត់លក្ខខណ្ឌក្រោមកថាខ័ណ្ឌ ១ ត្រូវចាប់ផ្តើមពិគ្រោះយោបល់ជាមួយរដ្ឋសមាជិកដទៃទៀត ដែលស្នើសុំនូវកិច្ចពិគ្រោះយោបល់នោះ ដើម្បីនឹងសើរើឡើងវិញនូវការកំណត់លក្ខខណ្ឌដែលខ្លួនបានដាក់កន្លងមក ។

## មាត្រា ១៧

## "ការលើកលែងទូទៅ"

១. អនុលោមតាមតំរូវការដែលវិធានការទាំងនេះ មិនអនុវត្តក្រោមរូបភាពជាមធ្យោបាយរើសអើងគ្មានមូលដ្ឋាន ឬមិនសមហេតុផលរវាងរដ្ឋសមាជិកទាំងអស់ ឬអ្នកវិនិយោគរបស់ពួកគេ ទីដែលស្ថានភាពដូចនេះ មានប្រៀប ឬការកំណត់លក្ខខណ្ឌក្លែងបន្លំចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃណាមួយ និងការវិនិយោគរបស់ពួកគេ គ្មានអ្វីៗនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយដើម្បីហាមឃាត់ចំពោះការអនុម័ត ឬការអនុវត្តនី ដោយរដ្ឋសមាជិកណាមួយនូវវិធានការ :

(ក) ចាំបាច់ ដើម្បីការពារសីលធម៌សាធារណៈ ឬដើម្បីថែរក្សានូវសណ្តាប់ធ្នាប់សាធារណៈ[១២]

(ខ) ចាំបាច់ ដើម្បីការពារជីវិត ឬសុខភាពរបស់មនុស្ស សត្វ ឬរុក្ខជាតិ

(គ) ចាំបាច់ ដើម្បីធានាបាននូវការគោរពតាមច្បាប់ ឬបទប្បញ្ញត្តិ ដែលមិនមានសង្កត់ភាពជាមួយកិច្ចព្រមព្រៀងនេះ រាប់បញ្ចូលទាំងបញ្ហាពាក់ព័ន្ធដូចខាងក្រោម :

---

[១២] ការលើកលែងចំពោះសណ្តាប់ធ្នាប់សាធារណៈ អាចត្រូវបានសំអាងដោយរដ្ឋសមាជិកមួយ ចំពោះតែការគំរាមកំហែងធ្ងន់ធ្ងរពិតប្រាកដ ដែលត្រូវបានចាត់ទុកថាជាគ្រោះគំរាមកំហែងជាមូលដ្ឋានដល់សង្គម ។

(i) ទប់ស្កាត់ការប្រព្រឹត្តិនូវអំពើឆបោក និងការលួចបន្លំដើម្បីដោះស្រាយផលប៉ះពាល់នៃការមិនអនុវត្តតាមកិច្ចសន្យា

(ii) ការការពារឯកជនភាពនៃបុគ្គល ទាក់ទងនឹងដំណើរការ និងការផ្សព្វផ្សាយទិន្នន័យផ្ទាល់ខ្លួន និងការការពារការសំងាត់នៃប្រវត្តិ និងគណនីរបស់បុគ្គល

(iii) សុវត្ថិភាព

(ឃ) មានគោលបំណងធានានូវការដាក់កំហិតឱ្យបង់ពន្ធ ឬការប្រមូល ប្រកបដោយសមធម៌ ឬប្រសិទ្ធិភាព[១៣] នូវពន្ធដារផ្ទាល់ ទាក់ទងនឹងការវិនិយោគ ឬអ្នកវិនិយោគនៃរដ្ឋសមាជិកណាមួយ

(ង) តំរូវឱ្យការការពាររតនភ័ណ្ឌជាតិដែលមានតម្លៃខាងសិល្បៈ តម្លៃខាងប្រវត្តិសាស្ត្រ ឬ តម្លៃខាងបុរាណវត្ថុវិទ្យា

(ច) ទាក់ទងនឹងការអភិរក្សធនធានធម្មជាតិដែលនឹងត្រូវបាត់បង់ ប្រសិនបើវិធានការទាំងនេះត្រូវបានធ្វើឡើងប្រកបដោយប្រសិទ្ធិភាពជាមួយនឹងការកំណត់លក្ខខណ្ឌលើផលិតកម្ម ឬការប្រើប្រាស់ ក្នុងស្រុក

២. ចំពោះវិធានការណាដែលជះឥទ្ធិពលលើការផ្គត់ផ្គង់សេវាកម្មហិរញ្ញវត្ថុ កថាខ័ណ្ឌ ២ (បទប្បញ្ញត្តិក្នុងស្រុក) នៃឧបសម្ព័ន្ធស្តីពីសេវាកម្មហិរញ្ញវត្ថុ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្ម ក្នុងសេវាកម្ម នៅក្នុងឧបសម្ព័ន្ធ 1ខ ចំពោះកិច្ចព្រមព្រៀង WTO (GATS) ត្រូវបញ្ចូលទៅក្នុង និងធ្វើជាផ្នែកទាំងស្រុងនៃកិច្ចព្រមព្រៀងនេះ mutatis mutandis ។

## មាត្រា ១៨

## "ការលើកលែងចំពោះសន្តិសុខ"

ពុំមានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានបកស្រាយ :

(ក) ដើម្បីតម្រូវឱ្យរដ្ឋសមាជិកណាមួយផ្តល់ពត៌មានណា ប្រសិនបើរដ្ឋសមាជិកនោះ យល់ឃើញថា ការផ្តល់ពត៌មាននោះ ប៉ះពាល់ដល់បញ្ហាសន្តិសុខរបស់ខ្លួន

---

[១៣] សំរាប់គោលបំណងនៃអនុកថាខ័ណ្ឌនេះ កំណត់សំគាល់ ៦ នៃមាត្រា ១៤ នៃកិច្ចព្រមព្រៀងទូទៅស្តីពីពាណិជ្ជកម្មក្នុងសេវាកម្ម នៅក្នុងឧបសម្ព័ន្ធ 1ខ ចំពោះ កិច្ចព្រមព្រៀង WTO (GATS) ត្រូវបានបញ្ចូលទៅក្នុង និងបង្កើតបានជាផ្នែកទាំងមូល នៃកិច្ចព្រមព្រៀងនេះ ដូចគ្នានឹងកិច្ចព្រមព្រៀង WTO (GATS) ។

(ខ) ដើម្បីរារាំងរដ្ឋសមាជិកណាមួយ ក្នុងការធ្វើសកម្មភាពណាមួយដែលខ្លួនយល់ឃើញថា ចាំបាច់សំរាប់ការការពារសន្តិសុខរបស់ខ្លួន រាប់បញ្ចូលទាំង ប៉ុន្តែមិនកំណត់ចំពោះ :

(i) សកម្មភាពទាក់ទងនឹងសម្ភារៈដែលអាចផ្ទុះ និងអាចរលាយ ឬសំភារៈ ដែលមានប្រភពចេញពីសំភារៈខាងលើនេះ

(ii) សកម្មភាពទាក់ទងនឹងចរាចរអាវុធ គ្រាប់រំសេវ និងសញ្ញាវុធសង្គ្រាម នឹងចរាចរសម្ភារៈផ្សេង១ទៀត ដែលមានគោលបំណងផ្គត់ផ្គង់ដោយផ្ទាល់ ឬ ដោយប្រយោលដល់មូលដ្ឋានទ័

(iii) សកម្មភាព ដែលធ្វើឡើងក្នុងកាលៈទេសៈសង្គ្រាម ឬភាពអាសន្នផ្សេងទៀតក្នុងទំនាក់ទំនងក្នុងស្រុក ឬអន្តរជាតិ

(iv) សកម្មភាព ដែលធ្វើឡើងដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធសាធារណៈដ៏សំខាន់ រាប់បញ្ចូលទាំងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ថាមពល និងទឹក ពីការប៉ុនប៉ងដោយចេតនា សំដៅធ្វើឱ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ ឬ

(គ) ដើម្បីទប់ស្កាត់រដ្ឋសមាជិកណាមួយពីចំណាត់វិធានការណាមួយ ដោយយោងដល់កាតព្វកិច្ចដូចមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិសំរាប់ការថែរក្សាសន្តិភាព និងសន្តិសុខអន្តរជាតិ ។

## មាត្រា ១៩

## "ការបដិសេធផលប្រយោជន៍"

១. រដ្ឋសមាជិកមួយ អាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ ចំពោះ :

(ក) អ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដែលជានីតិបុគ្គលមួយនៃរដ្ឋសមាជិកដទៃទៀត និងចំពោះការវិនិយោគនៃអ្នកវិនិយោគនោះ ប្រសិនបើអ្នកវិនិយោគ នៃរដ្ឋមិនមែនជា សមាជិកធ្វើជាម្ចាស់កម្មសិទ្ធិ ឬគ្រួតត្រាលើនីតិបុគ្គល ហើយនីតិបុគ្គល ពុំមានប្រតិបត្តិការធុរៈកិច្ចសំខាន់នៅក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀតនោះ ។

(ខ) អ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដែលជានីតិបុគ្គលនៃរដ្ឋសមាជិកដទៃទៀត និងចំពោះការវិនិយោគនៃអ្នកវិនិយោគនោះ ប្រសិនបើអ្នកវិនិយោគនៃរដ្ឋសមាជិកដែលបដិសេធកាន់កាប់ ឬគ្រួតត្រាលើនីតិបុគ្គល ហើយនីតិបុគ្គលនោះពុំមានប្រតិបត្តិការធុរៈកិច្ចសំខាន់នៅក្នុងដែនដីនៃរដ្ឋសមាជិកដទៃទៀតនោះ

(គ) អ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដែលជានីតិបុគ្គលនៃរដ្ឋសមាជិកដទៃទៀត និងចំពោះការវិនិយោគនៃអ្នកវិនិយោគនោះ ប្រសិនបើអ្នកវិនិយោគនៃរដ្ឋមិនមែនសមាជិកកាន់កាប់

ឬត្រួតត្រានីតិបុគ្គល ហើយរដ្ឋសមាជិកដែលបដិសេធ ពុំមានចំណងទាក់ទងការទូតជាមួយរដ្ឋមិនមែនសមាជិក ។

២. ក្រោយពីការជូនដំណឹង ចំពោះរដ្ឋសមាជិកនៃអ្នកវិនិយោគ និងគ្មានការប៉ះពាល់ដល់កថាខ័ណ្ឌ ១ រដ្ឋសមាជិកមួយ អាចបដិសេធផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត និងចំពោះការវិនិយោគនៃអ្នកវិនិយោគនោះ ដែលអ្នកវិនិយោគនោះធ្វើការវិនិយោគ ដោយរំលោភលើច្បាប់ក្នុងស្រុក នៃរដ្ឋសមាជិកដែលធ្វើការបដិសេធនោះ ដោយផ្តល់ពត៌មានខុសពីម្ចាស់កម្មសិទ្ធិរបស់ខ្លួន ក្នុងតំបន់វិនិយោគ ដែលត្រូវបានបំរុងទុកសំរាប់រូបវ័ន្តបុគ្គល ឬនីតិបុគ្គលនៃរដ្ឋសមាជិកដែលបដិសេធ ។

៣. នីតិបុគ្គលមួយ ត្រូវ :

(ក) "កាន់កាប់" ដោយអ្នកវិនិយោគ អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាតិនៃរដ្ឋសមាជិកនីមួយៗ

(ខ) "ត្រួតត្រា" ដោយអ្នកវិនិយោគ ប្រសិនបើអ្នកវិនិយោគ មានសិទ្ធិអំណាច ដើម្បីតែងតាំងគណៈកម្មាធិការនាយករបស់ខ្លួនលើសពីពាក់កណ្តាល ឬ ក្រៅពីនេះត្រួតត្រាស្របច្បាប់លើសកម្មភាពរបស់ការវិនិយោគទាំងនោះ ។

## មាត្រា ២០

## "ទម្រង់ការពិសេស និងការផ្តល់ពត៌មាន"

១. គ្មានអ្វីនៅក្នុងមាត្រា ៥ ("ប្រព្រឹត្តកម្មជាតិ") ឬ ៦ ("ប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត") ត្រូវបានបកស្រាយដើម្បីទប់ស្កាត់រដ្ឋសមាជិកមួយពីការអនុម័ត ឬការរក្សាទុកនូវវិធានការមួយ ដែលដាក់ប្បញ្ញត្តិនូវទម្រង់ការពិសេសទាក់ទងនឹងការវិនិយោគ ព្រមទាំងតម្រូវការដែលការវិនិយោគ ត្រូវមានលក្ខណៈស្របច្បាប់ ឬ មានទម្រង់ច្បាប់ជាក់លាក់ណាមួយ ក្រោមច្បាប់ ឬបទប្បញ្ញត្តិនៃរដ្ឋសមាជិក និងការប្រព្រឹត្តតាម ការតម្រូវការចំពោះការចុះបញ្ជី ឱ្យតែទម្រង់ការនោះ មិនមានអ្វីខូចខាតធ្ងន់ធ្ងរចំពោះសិទ្ធិ ដែលត្រូវបានផ្តល់ ដោយរដ្ឋសមាជិកមួយ ចំពោះអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត និងការវិនិយោគ ស្របតាមកិច្ចព្រមព្រៀងនេះ ។

២. ថ្វីបើមានចែងក្នុងមាត្រា ៥ ("ប្រព្រឹត្តកម្មជាតិ") ឬ ៦ ("ប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត") ក៏ដោយ រដ្ឋសមាជិកមួយ អាចតម្រូវឱ្យអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ឬ ដៃវិនិយោគ ក្នុងការផ្តល់ពត៌មានពាក់ព័ន្ធនឹងការវិនិយោគនោះ ដើម្បីគោលបំណងពត៌មានឬស្ថិតិតែប៉ុណ្ណោះ ។ រដ្ឋសមាជិក អាចការពារចំពោះពត៌

មានសម្ងាត់ ពីការផ្សព្វផ្សាយ ដែលនឹងប៉ះពាល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់ ឬនីតិបុគ្គលសាធារណៈ ឬនីតិបុគ្គលឯកជនណាមួយ ឬ ស្ថានភាពប្រកួតប្រជែងនៃអ្នកវិនិយោគ ឬដែនវិនិយោគ ។

គ្មានអ្វីនៅក្នុងកថាខ័ណ្ឌនេះ ដែលត្រូវបានបកស្រាយដើម្បីរាំងរដ្ឋសមាជិកមួយពីការទទួលបាន ឬផ្តល់ពត៌មានស្របតាមការអនុវត្តន៍ ប្រកបដោយសមភាពនិងបំណងល្អនៃច្បាប់របស់ខ្លួន ។

## មាត្រា ២១

## "តម្លាភាព"

១. ដើម្បីនឹងសំរេចបាននូវគោលបំណងនៃកិច្ចព្រមព្រៀងនេះ រដ្ឋសមាជិកនីមួយៗ ត្រូវ :

(ក) ជូនដំណឹងទៅក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ជាបន្ទាន់ និងយ៉ាងហោចណាស់មួយឆ្នាំម្តង នូវ កិច្ចព្រមព្រៀងណាមួយដែលទាក់ទងនឹងការវិនិយោគ ឬការរៀបចំណាមួយ ដែលសំរេចបាន ហើយដែលវាបានផ្តល់នូវប្រព្រឹត្តកម្មដែលមានលក្ខណៈអនុគ្រោះ

(ខ) ជូនដំណឹងទៅក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ជាបន្ទាន់ និងយ៉ាងហោចណាស់មួយឆ្នាំម្តង នូវ ច្បាប់ថ្មី ឬការប្រែប្រួលចំពោះច្បាប់ដែលមានស្រាប់ បទប្បញ្ញត្តិ ឬគោលការណ៍ណែនាំរដ្ឋបាល ដែលជះឥទ្ធិពលដល់ការវិនិយោគ ឬការប្តេជ្ញានៃរដ្ឋសមាជិកក្រោមកិច្ចព្រមព្រៀងនេះ ។

(គ) ផ្សព្វផ្សាយជាសាធារណៈនូវច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំរដ្ឋបាលពាក់ព័ន្ធនានាទាំងអស់ នៃការអនុវត្តន៍ទូទៅទាក់ទងនឹង ឬជះឥទ្ធិពលដល់ការវិនិយោគនៅក្នុងដែនដីនៃរដ្ឋសមាជិក ហើយ

(ឃ) បង្កើត ឬចាត់តាំងចំណុចទំនាក់ទំនង សំរាប់ផ្តល់រាល់ពត៌មានទាក់ទងនឹងវិធានការ ដែលតម្រូវឱ្យមានការបោះពុម្ពផ្សាយ ឬផ្សព្វផ្សាយជាសាធារណៈ ក្រោមអនុកថាខ័ណ្ឌ (ខ) និង (គ) តាមសំណើរបស់រូបវន្តបុគ្គល នីតិបុគ្គល ឬរដ្ឋសមាជិកដទៃទៀត ដើម្បីអាចទទួលបានភ្លាមៗ ។

២. គ្មានអ្វីនៅក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបានទាមទារឱ្យរដ្ឋសមាជិកផ្តល់ ឬបង្កលទ្ធភាពឱ្យទទួលបាននូវពត៌មានសម្ងាត់ណាមួយ រាប់បញ្ចូលទាំងពត៌មានទាក់ទងនឹងការវិនិយោគ និងអ្នកវិនិយោគ ប្រសិនបើការផ្តល់ពត៌មាននេះ ធ្វើឱ្យរាំងស្ទះដល់ការអនុវត្តន៍ច្បាប់ ឬ ផ្ទុយទៅនឹងផលប្រយោជន៍សាធារណៈ ឬប៉ះពាល់ដល់ផលប្រយោជន៍ពាណិជ្ជកម្មស្របច្បាប់របស់នីតិបុគ្គលពិសេស ឬ នីតិបុគ្គលសាធារណៈ ឬឯកជនណាមួយ ។

## មាត្រា ២២
## ការចេញចូល ស្នាក់នៅបណ្តោះអាសន្ន និងការងារនៃអ្នកវិនិយោគ និងបុគ្គលិកសំខាន់ៗ"

អនុលោមតាមច្បាប់ ការងារ និងអន្តោប្រវេសន៍ បទប្បញ្ញត្តិនានា និងគោលនយោបាយជាតិ ទាក់ទងនឹងការចេញចូល ការស្នាក់នៅបណ្តោះអាសន្ន និងការអនុញ្ញាតិឱ្យធ្វើការ និងស្របតាមការប្តេជ្ញារបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីសេវាកម្ម រដ្ឋសមាជិកនីមួយៗ ត្រូវផ្តល់ការចេញ-ចូល ស្នាក់នៅបណ្តោះអាសន្ន និងការអនុញ្ញាតិឱ្យធ្វើការចំពោះអ្នកវិនិយោគ សមាជិកនៃគណៈនាយក អ្នកគ្រប់គ្រង និងសមាជិកនៃក្រុមប្រឹក្សាភិបាល នៃនីតិបុគ្គលមួយនៃរដ្ឋសមាជិកដទៃទៀត សំរាប់គោលបំណងបង្កើត អភិវឌ្ឍន៍ ចាត់ចែងការងារ ឬផ្តល់ការប្រឹក្សាស្តីពីកិច្ចប្រតិបត្តិការក្នុងដែនដីនៃរដ្ឋសមាជិក នៃការវិនិយោគមួយ ដែលពួកគេ ឬនីតិបុគ្គលនៃរដ្ឋសមាជិកដទៃទៀត ដែលជួលអ្នកគ្រប់គ្រង នាយកប្រតិបត្តិ និងសមាជិកនៃក្រុមប្រឹក្សាភិបាល ដែលបានប្តេជ្ញា ឬស្ថិតក្នុងដំណើរការនៃការប្តេជ្ញានូវចំនួនដ៏ធំចេងនៃមូលធន ឬធនធានដទៃទៀត ។

## មាត្រា ២៣
## "ប្រព្រឹត្តកម្មពិសេស និងដោយឡែក សំរាប់រដ្ឋសមាជិកអាស៊ានថ្មី"

ដើម្បីបង្កើននូវផលប្រយោជន៍នៃកិច្ចព្រមព្រៀងនេះ សំរាប់រដ្ឋសមាជិកអាស៊ានថ្មី និងអនុលោមតាមគោលបំណង និងគោលការណ៍ ដែលមានចែងក្នុងបុព្វកថា និងមាត្រា ១ ("គោលបំណង") និង ២ "គោលការណ៍ណែនាំ") រដ្ឋសមាជិក ទទួលស្គាល់នូវសារៈសំខាន់នៃការផ្តល់ជូននូវប្រព្រឹត្តកម្មពិសេស និងដោយឡែកចំពោះរដ្ឋសមាជិកអាស៊ានថ្មី តាមរយៈ :

(ក) ជំនួយបច្ចេកទេស ដើម្បីពង្រឹងសមត្ថភាពពួកគេ ទាក់ទងនឹងគោលនយោបាយ និងការជំរុញការវិនិយោគ ក្នុងតំបន់នានាដូចជាការអភិវឌ្ឍន៍ធនធានមនុស្ស

(ខ) ការប្តេជ្ញានានា ក្នុងក្របខ័ណ្ឌនៃផលប្រយោជន៍ចំពោះរដ្ឋសមាជិកអាស៊ានថ្មី ហើយ

(គ) ទទួលស្គាល់ថា ការប្តេជ្ញា ដោយរដ្ឋសមាជិកអាស៊ានថ្មីនីមួយៗ អាចត្រូវបានធ្វើឡើង ដោយអនុលោមតាមដំណាក់កាលអភិវឌ្ឍន៍រៀងៗខ្លួន ។

## មាត្រា ២៤
## "ការជំរុញការវិនិយោគ"

រដ្ឋសមាជិក ត្រូវធ្វើសហប្រតិបត្តិការក្នុងការបង្កើនការយល់ដឹងទូលំទូលាយពីអាស៊ាន ជាតំបន់វិនិយោគ ដែលមានសមាហរណកម្ម ដើម្បីនឹងបង្កើនបាននូវការវិនិយោគបរទេសចូលក្នុងអាស៊ាន និងការវិនិយោគក្នុងចំណោមអាស៊ាន តាមរយៈ :

(ក) ជំរុញឱ្យមានកំណើន និងកិច្ចអភិវឌ្ឍន៍នៃសហគ្រាសតូច-មធ្យម និងសហគ្រាសពហុជាតិរបស់អាស៊ាន

(ខ) ពង្រីកការបំពេញឱ្យគ្នាទៅវិញទៅមកនូវផ្នែកឧស្សាហកម្ម និងបណ្តាញផលិតកម្ម ក្នុងចំណោម សហគ្រាសពហុជាតិនៅក្នុងអាស៊ាន

(គ) រៀបចំបេសកកម្មវិនិយោគដែលផ្តោតជាសំខាន់លើកិច្ចអភិវឌ្ឍន៍នូវបណ្តាមុខសញ្ញាជាគន្លឹះក្នុងតំបន់ និងបណ្តាញផលិតកម្ម

(ឃ) រៀបចំ និងគាំទ្រដល់ការចាត់ចែងឱ្យមានការជួបសំណេះសំណាលពិគ្រោះយោបល់ជាសង្ខេបផ្សេងៗ និងជាសិក្ខាសាលាស្តីពីកាលានុវត្តន៍ភាពវិនិយោគ និងស្តីពីច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយវិនិយោគ

(ង) ធ្វើកម្មវិធីពិភាក្សាស្តីពីបញ្ហាផ្សេងៗដែលជាកង្វល់ទៅវិញទៅមកទាក់ទងនឹងការជំរុញការវិនិយោគ ។

## មាត្រា ២៥
## "កិច្ចសម្រួលនៃការវិនិយោគ"

រដ្ឋសមាជិក ត្រូវប្រឹងប្រែងធ្វើសហប្រតិបត្តិការក្នុងកិច្ចសម្រួលនៃការវិនិយោគជាមួយ និងក្នុងអាស៊ានតាមរយៈ :

(ក) បង្កើតឡើងនូវបរិស្ថានចាំបាច់សំរាប់គ្រប់ទម្រង់នៃការវិនិយោគ

(ខ) សំរួល និងធ្វើឱ្យកាន់តែសាមញ្ញនូវនីតិវិធីសំរាប់ការបំពេញបែបបទ និងការអនុម័តការវិនិយោគ

(គ) ជំរុញការផ្សាយពត៌មានវិនិយោគ រាប់បញ្ចូលទាំងវិធាន បទប្បញ្ញត្តិ គោលនយោបាយ និងនីតិវិធីនៃការវិនិយោគ

(ឃ) បង្កើតនូវមជ្ឈមណ្ឌលវិនិយោគជាច្រកចេញ-ចូលតែមួយ

(ង) ពង្រឹងទិន្នន័យសំរាប់គ្រប់ទម្រង់នៃការវិនិយោគសំរាប់រៀបចំចងក្រងជាគោលនយោបាយ ដើម្បីកែលំអបរិស្ថានវិនិយោគរបស់អាស៊ាន

(ច) ធ្វើការពិគ្រោះយោបល់ជាមួយសហគមន៍ធុរៈកិច្ចស្តីពីបញ្ហាវិនិយោគ ហើយ

(ឆ) ផ្តល់សេវាកម្មប្រឹក្សាជូនសហគមន៍ធុរៈកិច្ចនៃរដ្ឋសមាជិកដទៃទៀត

## មាត្រា ២៦

## "ពង្រីកសមាហរណកម្មអាស៊ាន"

រដ្ឋសមាជិក ទទួលស្គាល់នូវសារៈសំខាន់នៃការជំរុញឱ្យចំរើនឡើងនូវសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន តាមរយៈគំនិតផ្តួចផ្តើមផ្សេងៗ រាប់បញ្ចូលទាំងគំនិតផ្តួចផ្តើមសំរាប់សមាហរណកម្មអាស៊ាន វិស័យជាអាទិភាព សំរាប់ធ្វើសមាហរណកម្ម និងសហគមន៍សេដ្ឋកិច្ចអាស៊ាន ដែលទាំងអស់នោះ មានរាប់បញ្ចូលនូវកិច្ចសហប្រតិ-បត្តិការស្តីពីវិនិយោគ ។ ដើម្បីពង្រីកសមាហរណកម្មសេដ្ឋកិច្ចអាស៊ាន រដ្ឋសមាជិកទាំងអស់ ត្រូវប្រឹងប្រែង សំដៅ :

(ក) ធ្វើសុខដុមកម្ម តាមដែលអាចធ្វើទៅបាននូវវិធានការ និងគោលនយោបាយវិនិយោគ ដើម្បីសំរេចបាននូវការបំពេញឱ្យគ្នាទៅវិញទៅមកផ្នែកឧស្សាហកម្ម

(ខ) ស្ថាបនា និងពង្រឹងសមត្ថភាពនៃរដ្ឋសមាជិកទាំងអស់ រួមទាំងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ក្នុងការរៀបចំ និងកែលំអគោលនយោបាយវិនិយោគ ដើម្បីទាក់ទាញការវិនិយោគ

(គ) ចែករំលែកពត៌មានស្តីពីគោលនយោបាយ និងការអនុវត្តន៍ដ៏ប្រសើរនៃការវិនិយោគ រួមទាំងសកម្មភាព និងឧស្សាហកម្ម ដែលត្រូវបានជំរុញ ហើយ

(ឃ) គាំទ្រកិច្ចខិតខំប្រឹងប្រែងនៃការជំរុញការវិនិយោគក្នុងចំណោមរដ្ឋសមាជិកសំរាប់ ផលប្រយោជន៍ទៅវិញទៅមក

## មាត្រា ២៧

## "វិវាទរវាង ឬក្នុងចំណោមរដ្ឋសមាជិក"

ពិធីសារអាស៊ាន ស្តីពីការធ្វើឱ្យប្រសើរឡើងនូវយន្តការដោះស្រាយវិវាទ ដែលបានចុះហត្ថលេខានៅទីក្រុង វៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ កាលពីថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ដូចបានធ្វើ វិសោធនកម្ម ត្រូវអនុវត្តចំពោះការដោះស្រាយវិវាទ ពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍នៃកិច្ចព្រម ព្រៀងនេះ ។

## ផ្នែក "ខ"

## ទីតាំងវិនិយោគរបស់អ្នកវិនិយោគ និងរដ្ឋសមាជិកមួយ

### មាត្រា ២៨

### "និយមន័យ"

សំរាប់គោលបំណងនៃផ្នែកនេះ :

(ក) **"អាជ្ញាធរមានសមត្ថកិច្ច"** មានន័យថា :

(i) ក្នុងករណីនៃមជ្ឈត្តវិនិច្ឆ័យ ក្រោមមាត្រា ៣៣(១)(ខ) ឬ(គ) អគ្គលេខាធិការនៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទផ្នែកវិនិយោគ

(ii) ក្នុងករណីនៃមជ្ឈត្តវិនិច្ឆ័យ ក្រោមមាត្រា ៣៣(១)(ឃ) អគ្គលេខាធិការនៃតុលាការអចិន្ត្រៃយ៍នៃមជ្ឈត្តវិនិច្ឆ័យ ឬ

(iii) ក្នុងករណីនៃមជ្ឈត្តវិនិច្ឆ័យ ក្រោមមាត្រា ៣៣(១)(ង) និង(ច) អគ្គលេខាធិការ ឬបុគ្គលដែលកាន់តំណែងប្រហាក់ប្រហែល នៃមជ្ឈមណ្ឌល ឬស្ថាប័នមជ្ឈត្តវិនិច្ឆ័យ

(ខ) **"អ្នកវិនិយោគមានវិវាទ"** មានន័យថា អ្នកវិនិយោគនៃរដ្ឋសមាជិកមួយ ដែលធ្វើបណ្តឹងក្នុងនាមខ្លួនឯងផ្ទាល់ ក្រោមផ្នែកនេះ រាប់បញ្ចូលទាំងអ្នកវិនិយោគនៃរដ្ឋសមាជិកមួយដែលធ្វើបណ្តឹងក្នុង នាមនីតិបុគ្គលនៃរដ្ឋសមាជិកដទៃទៀតដែលអ្នកវិនិយោគកាន់កាប់ ឬត្រួតត្រា

(គ) **"រដ្ឋសមាជិកមានវិវាទ"** មានន័យថា រដ្ឋសមាជិកមួយប្រឆាំងនឹងបណ្តឹងដែលត្រូវបានធ្វើឡើងក្រោមផ្នែកនេះ

(ឃ) **"ភាគីមានវិវាទ"** មានន័យថា អ្នកវិនិយោគមានវិវាទ និងរដ្ឋសមាជិកមានវិវាទ

(ង) "ICSID" មានន័យថា មជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទផ្នែកវិនិយោគ

(ច) **"វិធានជាយន្តការបន្ថែមរបស់ ICSID"** មានន័យថា វិធាន ដែលគ្រប់គ្រងយន្តការបន្ថែមសំរាប់រដ្ឋបាលនៃដំណើរការក្តីដោយលេខាធិការដ្ឋាននៃមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទផ្នែកវិនិយោគ

(ឆ) **"អនុសញ្ញា ICSID"** មានន័យថា អនុសញ្ញាស្តីពីការដោះស្រាយវិវាទផ្នែកវិនិយោគរវាងរដ្ឋ និងជនជាតិនៃរដ្ឋដទៃទៀត ដែលបានធ្វើឡើងនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក នាថ្ងៃទី ១៨ ខែមីនា ឆ្នាំ១៩៦៥

(ជ) "អនុសញ្ញាញូយ៉ក" មានន័យថា អនុសញ្ញាសហប្រជាជាតិស្តីពីការទទួលស្គាល់ និងការអនុវត្តន៍សាលក្រមមជ្ឈត្តកវិនិច្ឆ័យបរទេស ដែលបានធ្វើឡើងនៅទីក្រុងញូយ៉ក សហរដ្ឋអាមេរិក នាថ្ងៃទី ១០ ខែមិថុនា ឆ្នាំ១៩៥៨

(ឈ) "រដ្ឋសមាជិកមិនមានវិវាទ" មានន័យថា រដ្ឋសមាជិកនៃអ្នកវិនិយោគដែលកំពុងមានវិវាទ និង

(ញ) "វិធានមជ្ឈត្តកវិនិច្ឆ័យ UNCITRAL" មានន័យថា វិធានមជ្ឈត្តកវិនិច្ឆ័យនៃគណៈកម្មការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ដែលបានអនុម័តដោយសន្និបាតនៃសហប្រជាជាតិ នៅថ្ងៃទី ១៥ ខែធ្នូ ឆ្នាំ១៩៧៦ ។

## មាត្រា ២៩

## "វិសាលភាពនៃការគ្របដណ្តប់"

១. ផ្នែកនេះ ត្រូវអនុវត្តចំពោះវិវាទវិនិយោគរវាងរដ្ឋសមាជិក និងអ្នកវិនិយោគនៃរដ្ឋសមាជិកដទៃទៀត ដែលបានទទួលរងការខូចខាត ឬ បាត់បង់ ដោយមូលហេតុនៃការប្រព្រឹត្តល្មើសទៅនឹងសិទ្ធិ ដែលត្រូវបានផ្តល់ឱ្យដោយកិច្ចព្រមព្រៀងនេះ ទាក់ទងនឹងការវិនិយោគនៃអ្នកវិនិយោគនោះ ។

២. រូបវន្តបុគ្គល មានសញ្ជាតិ ឬជាជនជាតិនៃរដ្ឋសមាជិកមួយ មិនត្រូវដាក់បណ្តឹងប្រឆាំងនឹងរដ្ឋជាសមាជិកនោះ នៅក្រោមផ្នែកនេះឡើយ ។

៣. ផ្នែកនេះ នឹងមិនអនុវត្តចំពោះបណ្តឹងដែលលើកឡើងក្រៅពីព្រឹត្តិការណ៍ដែលបានកើតមាន ឬបណ្តឹងដែលបានត្រូវលើកឡើង មុនពេលការចូលជាធរមាននៃកិច្ចព្រមព្រៀងនេះទេ ។

៤. គ្មានអ្វីនៅក្នុងផ្នែកនេះ ត្រូវបានបកស្រាយដើម្បីទប់ស្កាត់អ្នកវិនិយោគមានវិវាទពីការស្វែងរកដំណោះស្រាយរដ្ឋបាល ឬតុលាការ ដែលមាននៅក្នុងប្រទេសនៃរដ្ឋសមាជិកមានវិវាទនោះឡើយ ។

## មាត្រា ៣០

## "ការផ្សះផ្សាគ្នា"

១. ភាគីមានវិវាទ អាចយល់ព្រមនៅពេលណាក៏បាន ដើម្បីឱ្យមានការផ្សះផ្សាគ្នា ដែលអាចចាប់ផ្តើមនៅពេលណាក៏បាន និងត្រូវបានបញ្ចប់ក្តីនៅពេលមានសំណើនៃអ្នកវិនិយោគមានវិវាទក្នុងពេលណាក៏បាន ។

២. ប្រសិនបើ ភាគីមានវិវាទ យល់ព្រម នីតិវិធីសំរាប់ការផ្សះផ្សាគ្នា អាចបន្ត ខណៈដែលនីតិវិធីមានចែងក្នុងមាត្រា ៣៣ ("ការដាក់ពាក្យបណ្តឹង") កំពុងដំណើរការ ។

៣. ដំណើរការក្តីទាក់ទងនឹងការផ្សះផ្សាគ្នា និងជំហរដែលប្រកាន់យកដោយភាគីមានវិវាទក្នុងពេលដំណើរការក្តីទាំងនេះ ត្រូវតែគ្មានផលប៉ះពាល់ ចំពោះសិទ្ធិនៃភាគីមានវិវាទណាមួយ ក្នុងដំណើរការក្តីក្រោមផ្នែកនេះ ។

## មាត្រា ៣១
## "ការពិគ្រោះយោបល់"

១. ក្នុងព្រឹត្តិការណ៍នៃវិវាទវិនិយោគមួយ ភាគីមានវិវាទ ត្រូវស្វែងរកជាបឋមដើម្បីដោះស្រាយវិវាទតាមរយៈការពិគ្រោះយោបល់ និងការចរចា ដែលអាចរាប់បញ្ចូលទាំងការប្រើប្រាស់នីតិវិធីនៃភាគីទីបី ដែលពុំមានចែងដោយច្បាប់ ។ ការពិគ្រោះយោបល់ទាំងនោះ ត្រូវតែផ្តើមចេញពីសំណើជាលាយលក្ខណ៍អក្សរសំរាប់ការពិគ្រោះយោបល់ ដែលផ្តល់ដោយអ្នកវិនិយោគមានវិវាទ ទៅរដ្ឋសមាជិកមានវិវាទ ។

២. ការពិគ្រោះយោបល់ ត្រូវចាប់ផ្តើមក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីបានទទួលសំណើសំរាប់ការពិគ្រោះយោបល់ពីរដ្ឋសមាជិកមានវិវាទ លើកលែងតែភាគីមានវិវាទយល់ព្រមក្រៅពីនេះ ។

៣. ដោយមានបំណងដោះស្រាយវិវាទវិនិយោគតាមរយៈការពិគ្រោះយោបល់នោះ អ្នកវិនិយោគមានវិវាទត្រូវប្រឹងប្រែងផ្តល់ពតិមានទាក់ទងនឹងច្បាប់ និងអង្គហេតុសំរាប់វិវាទវិនិយោគ ជូនរដ្ឋសមាជិកមានវិវាទ មុនការចាប់ផ្តើមនៃការពិគ្រោះយោបល់ ។

## មាត្រា ៣២
## "បណ្តឹងទាមទារដោយអ្នកវិនិយោគនៃរដ្ឋសមាជិកមួយ"

ប្រសិនបើវិវាទវិនិយោគមួយ មិនត្រូវបានដោះស្រាយក្នុងរយៈពេល ១៨០ ( មួយរយប៉ែតសិប) ថ្ងៃ ចាប់តាំងពីថ្ងៃរដ្ឋសមាជិកមានវិវាទទទួលសំណើសំរាប់ការពិគ្រោះយោបល់ យោងតាមផ្នែកនេះ អ្នកវិនិយោគមានវិវាទអាចដាក់បណ្តឹងទាមទារទៅមជ្ឈត្តវិនិច្ឆ័យ :

(ក) ថា រដ្ឋសមាជិកមានវិវាទ ខកខានមិនបានបំពេញកាតព្វកិច្ចដែលមានចែងក្នុងមាត្រា ៥ ("ប្រព្រឹត្តកម្មជាតិ") ៦ ("ប្រព្រឹត្តកម្មជាតិអនុគ្រោះបំផុត") ៨ ("អ្នកគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាល") ១១ ("ប្រព្រឹត្តកម្មវិនិយោគ") ១២ ("សំណងក្នុងករណីមានកលយុគ") ១៣ ("ការផ្ទេរ") និង ១៤ ("ការដកហូត និងសំណង") ទាក់ទងនឹងការគ្រប់គ្រង ទង្វើ ប្រតិបត្តិការ ឬ លក់ ឬ ការរំលាយដទៃទៀត នៃដែនវិនិយោគ និង

(ខ) ថា អ្នកវិនិយោគមានវិវាទបានរងការបាត់បង់ ឬខូចខាត ទាក់ទងនឹងដែនវិនិយោគរបស់ខ្លួន ដោយមូលហេតុ មកពីការខកខានមិនបានបំពេញកាតព្វកិច្ចក្នុងកិច្ចសន្យា ។

## មាត្រា ៣៣
## "ការដាក់ពាក្យបណ្តឹងទាមទារ"

. អ្នកវិនិយោគមានវិវាទ អាចដាក់ពាក្យបណ្តឹងទាមទារ ដោយយោងទៅលើមាត្រា ៣២ ("បណ្តឹងទាមទារដោយអ្នកវិនិយោគ នៃរដ្ឋសមាជិកមួយ") តាមជំរើសរបស់អ្នកវិនិយោគមានវិវាទ :

(ក) ទៅតុលាការ ឬសាលាជំរះក្តីតាមផ្លូវរដ្ឋបាល នៃរដ្ឋសមាជិកមានវិវាទ ប្រសិនបើ តុលាការ ឬសាលាជំរះក្តីនោះ មានអាជ្ញាយុកាលគ្រប់ដណ្តប់លើបណ្តឹងតវ៉ាទាំងនោះ ឬ

(ខ) ក្រោមអនុសញ្ញា ICSID និងវិធាន ICSID នៃនីតិវិធីសំរាប់ដំណើរការក្តីមជ្ឈត្តវិនិច្ឆ័យ[១៤] ប្រសិនបើ រដ្ឋសមាជិកមានវិវាទ និងរដ្ឋសមាជិកមិនមានវិវាទ ជាភាគីនៃអនុសញ្ញា ICSID ឬ

(គ) ក្រោមវិធានយន្តការបន្ថែមនៃ ICSID ប្រសិនបើ រដ្ឋសមាជិកមានវិវាទ ឬរដ្ឋសមាជិកមិនមានវិវាទ ជាភាគីមួយរបស់អនុសញ្ញា ICSID ឬ

(ឃ) ក្រោមវិធានមជ្ឈត្តវិនិច្ឆ័យនៃ UNCITRAL ឬ

(ង) ទៅមជ្ឈមណ្ឌលតំបន់សំរាប់មជ្ឈត្តវិនិច្ឆ័យនៅទីក្រុងគូឡាឡាំពួរ ឬមជ្ឈមណ្ឌលតំបន់ដទៃទៀតសំរាប់មជ្ឈត្តវិនិច្ឆ័យ នៅអាស៊ាន ឬ

(ច) ប្រសិនបើ ភាគីមានវិវាទយល់ព្រម ទៅស្ថាប័នមជ្ឈត្តវិនិច្ឆ័យដទៃទៀត

ទួលបាននូវវិធានមជ្ឈត្តវិនិច្ឆ័យណាមួយ ឬវេទិកា ក្រោមអនុកថាខ័ណ្ឌ ពី (ក) ដល់ (ច) នោះ មិនត្រូវអនុញ្ញាតប្រើប្រាស់ជំរើសផ្សេងទៀតបានឡើយ ។

. បណ្តឹងទាមទារមួយ ត្រូវបានចាត់ទុកថាបានដាក់ជូនទៅមជ្ឈត្តវិនិច្ឆ័យក្រោមផ្នែកនេះ នៅពេលដែលារជូនដំណឹងរបស់អ្នកវិនិយោគមានវិវាទ ឬសំណើសុំសំរាប់មជ្ឈត្តវិនិច្ឆ័យ ("ការជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យ") ត្រូវបានទទួលក្រោមវិធានមជ្ឈត្តវិនិច្ឆ័យដែលអាចអនុវត្តបាន ។

---

[១៤] ក្នុងករណី ប្រទេសហ្វីលីពីន ការដាក់ពាក្យបណ្តឹងទាមទារទៅ ICSID និង វិធាន ICSID នៃនីតិវិធីសំរាប់ដំណើរការក្តីមជ្ឈត្តវិនិច្ឆ័យ ត្រូវផ្អែកលើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីមានវិវាទក្នុងព្រឹត្តិការណ៍ដែលវិវាទវិនិយោគកើតឡើង ។

៣. វិធានមជ្ឈត្តវិនិច្ឆ័យដែលអាចអនុវត្តបាន ក្រោមកថាខ័ណ្ឌ ១ ត្រូវមានឥទ្ធិពលលើមជ្ឈត្តវិនិច្ឆ័យ លើកលែងតែមានការកែសម្រួលណាមួយដោយកិច្ចព្រមព្រៀងនេះ ដែលមានប្រសិទ្ធិភាពនៅថ្ងៃដែលបណ្តឹងទាមទារត្រូវបានដាក់ជូនសុំធ្វើមជ្ឈត្តវិនិច្ឆ័យក្រោមផ្នែកនេះ ។

៤. វិធានមជ្ឈត្តវិនិច្ឆ័យដែលអាចអនុវត្តបាន អាចត្រូវបានបដិសេធ ផ្លាស់ប្តូរ ឬកែប្រែ ដោយកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងភាគីមានវិវាទ ទាក់ទងនឹងវិវាទវិនិយោគជាក់លាក់ ឬថ្នាក់នៃវិវាទ ។ វិធានទាំងនោះ ត្រូវបានគោរពដោយសាលាជំរះក្តីពាក់ព័ន្ធ ដែលបានបង្កើតឡើងក្រោមផ្នែកនេះ និងដោយមជ្ឈត្តករផ្ទាល់នៅក្នុងសាលាជំរះក្តីនោះ ។

៥. អ្នកវិនិយោគមានវិវាទ ត្រូវផ្តល់ជូនមជ្ឈត្តវិនិច្ឆ័យនូវការប្រកាសអំពី :

(ក) ឈ្មោះនៃមជ្ឈត្តករដែលអ្នកវិនិយោគមានវិវាទតែងតាំង ឬ

(ខ) ការយល់ព្រមជាលាយលក្ខណ៍អក្សររបស់អ្នកវិនិយោគមានវិវាទសំរាប់អាជ្ញាធរមានសមត្ថកិច្ចដើម្បីតែងតាំងមជ្ឈត្តករនោះ ។

## មាត្រា ៣៤

## "លក្ខខណ្ឌ និងការកំរិតស្តីពីការដាក់ពាក្យបណ្តឹងទាមទារ"

១. វិវាទ ត្រូវដាក់ជូនទៅមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ៣៣(១)(ខ)ដល់(ច) អនុលោមតាមផ្នែកនេះ ហើយត្រូវមានលក្ខខណ្ឌដូចតទៅ :

(ក) ការដាក់សំណើនៃវិវាទវិនិយោគទៅមជ្ឈត្តវិនិច្ឆ័យទាំងនោះ ក្នុងរង្វង់ ៣ឆ្នាំ ចាប់ពីពេលដែលអ្នកវិនិយោគមានវិវាទបានដឹងដោយសមហេតុផល អំពីការខកខានមិនបានបំពេញកាតព្វកិច្ចក្រោមកិច្ចព្រមព្រៀងនេះ ដែលបណ្តាលឱ្យមានការបាត់បង់ ឬ ខូចខាត ដល់អ្នកវិនិយោគមានវិវាទ ឬ ដែនវិនិយោគ និង

(ខ) អ្នកវិនិយោគមានវិវាទ ផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរ ដែលត្រូវបានដាក់ជូនយ៉ាងតិច ៩០ ថ្ងៃមុនពេលបណ្តឹងទាមទារ ត្រូវបានដាក់ជូនចំពោះរដ្ឋសមាជិកមានវិវាទទៅមជ្ឈត្តវិនិច្ឆ័យនោះ នូវវិវាទវិនិយោគ ហើយ ដែលត្រូវធ្វើការសង្ខេបពីការចោទប្រកាន់អំពីការខកខានមិនបានបំពេញកាតព្វកិច្ច នៃរដ្ឋសមាជិកមានវិវាទ ក្រោមកិច្ចព្រមព្រៀងនេះ (រាប់បញ្ចូលទាំងបញ្ញត្តិ ដែលបានចោទ ប្រកាន់ថាបានខកខានមិនបំពេញកាតព្វកិច្ចផង) និងការបាត់បង់ ឬខូចខាត ដែលប៉ះពាល់ដល់ អ្នកវិនិយោគមានវិវាទ ឬដែនវិនិយោគ និង

(គ) ការជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យក្រោម មាត្រា ៣៣(២) អមដោយបណ្តឹងជាលាយលក្ខណ៍អក្សររបស់អ្នកវិនិយោគដែលមានវិវាទ ស្តីពីការលើកលែងសិទ្ធិរបស់អ្នកវិនិយោគមានវិវាទ ដើម្បីចាប់ផ្តើម ឬបន្តដំណើរការកាត់ក្តីណាមួយនៅមុខតុលាការ ឬតុលាការរដ្ឋបាលនៃរដ្ឋសមាជិកមានវិវាទ ឬនីតិវិធីដោះស្រាយវិវាទដទៃទៀត នៃដំណើរការកាត់ក្តីណាមួយទាក់ទងនឹងវិធានការណាមួយ ដែលអះអាងថាមានករណីរំលោភ យោងតាមមាត្រា ៣២ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃរដ្ឋសមាជិក) ។

២. ទោះបីមានចែងក្នុង អនុកថាខណ្ឌ ១(គ) អ្នកវិនិយោគមានវិវាទ មិនត្រូវបានទប់ស្កាត់ពីការចាប់ផ្តើម ឬបន្តសកម្មភាពដែលស្វែងរកវិធានការអន្តរកាលនៃការការពារសំរាប់គោលបំណងទោលនៃការការពារនូវសិទ្ធិ និងផលប្រយោជន៍របស់អ្នកវិនិយោគមានវិវាទ ព្រមទាំងគ្មានពាក់ព័ន្ធនឹងការទូទាត់នៃការខូចខាត ឬដំណោះស្រាយនៃបញ្ហាក្នុងវិវាទឡើយ នៅមុខតុលាការ ឬតុលាការរដ្ឋបាល នៃរដ្ឋសមាជិកមានវិវាទ។

៣. រដ្ឋសមាជិកមួយ មិនត្រូវផ្តល់ការការពារជាលក្ខណៈការទូត ឬ នាំយកបណ្តឹងទាមទារជាលក្ខណៈអន្តរជាតិ ទាក់ទងនឹងវិវាទមួយ ដែលភាគីមួយនៃអ្នកវិនិយោគរបស់ខ្លួន និងភាគីរដ្ឋសមាជិកដទៃ ទៀត បានយល់ព្រមដើម្បីបញ្ជូនសំណើ ឬបានបញ្ជូនសំណើទៅមជ្ឈត្តវិនិច្ឆ័យ ក្រោមផ្នែកនេះ លើកលែងតែ រដ្ឋសមាជិកដទៃទៀតនោះ មិនបានខកខានក្នុងការប្រព្រឹត្តតាម និងគោរពតាមសាលក្រមដែលប្រកាសក្នុងវិវាទនោះ ។ សំរាប់គោលបំណងនៃ កថាខ័ណ្ឌនេះ ការការពារជាលក្ខណៈការទូត មិនត្រូវរាប់បញ្ចូលនូវការផ្លាស់ប្តូរយោបល់ខាងការទូតមិនផ្លូវការ សំរាប់គោលបំណង ទោលនៃការសំរួលចំពោះដំណោះស្រាយនៃវិវាទទេ ។

៤. រដ្ឋសមាជិកមានវិវាទមួយ មិនត្រូវអះអាង ជាការការពារខ្លួន ជាបណ្តឹងតប ជាសិទ្ធិនៃការទាមទារទូទាត់ ឬជាករណីផ្សេងៗទៀតថា អ្នកវិនិយោគមានវិវាទទាក់ទងនឹងផែនវិនិយោគ បានទទួល ឬ នឹងទទួលយោងតាមកិច្ចសន្យាធានារ៉ាប់រង ឬកិច្ចសន្យាផ្តល់ការធានានូវសំណងជំងឺចិត្ត ឬការសងទាំងអស់ ឬ ជាផ្នែកនៃការខាតបង់ផ្សេងៗទៀត ។

## មាត្រា ៣៥

## "ការជ្រើសរើសមជ្ឈត្តករ"

១. លើកលែងតែ ភាគីមានវិវាទមិនយល់ព្រម ក្រៅពីនេះ តុលាការជំរះក្តី ត្រូវមានមជ្ឈត្តករចំនួនបីរូប :

(ក) ភាគីមានវិវាទនីមួយៗត្រូវតែងតាំង មជ្ឈត្តករមួយរូប និង

(ខ) មជ្ឈត្តករទីបី ដែលត្រូវជាមជ្ឈត្តករអធិបតី ត្រូវជ្រើសរើសដោយមានការឯកភាពពីភាគីមានវិវាទទាំងពីរ ។ មជ្ឈត្តករទីបី ត្រូវជាប្រជាជននៃរដ្ឋមិនមែនសមាជិក ដែលមានចំណងការទូតជាមួយរដ្ឋសមាជិកមានវិវាទ និងរដ្ឋមិនមែនសមាជិកមានវិវាទនិងមិនមានទីលំនៅអចិន្ត្រៃយ៍ក្នុងរដ្ឋសមាជិកមានវិវាទ ឬក្នុងរដ្ឋមិនមែនសមាជិកមានវិវាទទេ ។

២. បុគ្គលដែលត្រូវបានជ្រើសតាំងជាមជ្ឈត្តករ ត្រូវមានជំនាញ ឬបទពិសោធន៍ក្នុងច្បាប់អន្តរជាតិសាធារណៈ ពាណិជ្ជកម្មអន្តរជាតិ ឬវិធាននានានៃការវិនិយោគអន្តរជាតិ ។ មជ្ឈត្តករមួយ ត្រូវបានជ្រើសរើសយ៉ាងមធ្យ័តដោយផ្អែកទៅលើភាពមិនលំអៀង ភាពគួរឱ្យជឿទុកចិត្តបាន មានសុភវិនិច្ឆ័យក្នុងការវិនិច្ឆ័យ និងមានភាពឯករាជ្យ ហើយត្រូវប្រកាន់គោលជំហររបស់ខ្លួន លើមូលដ្ឋានដូចគ្នា នៅពេលដំណើរការមជ្ឈត្តវិនិច្ឆ័យ ។

៣. ផ្អែកតាមមាត្រា ៣៦ (ការប្រព្រឹត្តនៃមជ្ឈត្តវិនិច្ឆ័យ) ប្រសិនបើតុលាការជំរះក្តី មិនអាចបង្កើតបានក្នុងរយៈពេល ៧៥ថ្ងៃ រាប់ចាប់ពីថ្ងៃ ដែលបណ្តឹងទាមទារ ត្រូវបានប្រគល់ជូនទៅមជ្ឈត្តវិនិច្ឆ័យ ស្ថិតនៅក្រោមផ្នែកនេះ អាជ្ញាធរមានសមត្ថកិច្ច ដែលមានអំណាចតែងតាំងជំនួស ត្រូវជ្រើសតាំងមជ្ឈត្តករមួយរូប ឬច្រើនរូប ដែលមិនធ្លាប់បានតែងតាំងពីមុនមក តាមការស្នើសុំរបស់ភាគីមានវិវាទមួយ ។

៤. តុលាការជំរះក្តី ត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួន ដោយបោះឆ្នោតយកមតិសម្លេងភាគច្រើនដាច់ខាត ហើយសេចក្តីសំរេចរបស់ខ្លួន ត្រូវបានអនុវត្តដោយភាគីមានវិវាទ ។

៥. ភាគីមានវិវាទទាំងអស់ ត្រូវទទួលរ៉ាប់រងសេវាសំរាប់មជ្ឈត្តកររៀង១ខ្លួន ចំពោះតុលាការជំរះក្តី ហើយត្រូវមានចំណែកស្មើគ្នាលើសេវាសំរាប់មជ្ឈត្តករអធិបតី ព្រមទាំងសេវាពាក់ព័ន្ធផ្សេងទៀត ។ ក្នុងគ្រប់ទិដ្ឋភាពដទៃទៀត តុលាជំរះក្តី ត្រូវកំណត់នីតិវិធីធ្វើការផ្ទាល់ខ្លួន ។

៦. ភាគីមានវិវាទទាំងឡាយ អាចបង្កើតវិធាននានាពាក់ព័ន្ធលើការចំណាយក្នុងដំណើរការកាត់ក្តី រួមបញ្ចូលទាំងលាភការរបស់មជ្ឈត្តករ ។

៧. នៅពេលមជ្ឈត្តករណាមួយ ដែលត្រូវបានតែងតាំង ដូចបានចែងក្នុងមាត្រានេះ លាលែង ឬអសមត្ថភាពក្នុងការបំពេញការងារ អ្នកស្នង ត្រូវបានតែងតាំងក្នុងលក្ខខណ្ឌដូចគ្នា ដូចមានចែងក្នុងការតែងតាំងនៃមជ្ឈត្តករដើម ហើយអ្នកស្នង ត្រូវមានសិទ្ធិ និងករណីយកិច្ចទាំងអស់ពីមជ្ឈត្តករដើម ។

## មាត្រា ៣៦

## "ការប្រព្រឹត្តនៃមជ្ឈត្តវិនិច្ឆ័យ"

១. ពេលបញ្ហាពាក់ព័ន្ធនឹងយុត្តាធិការ ឬការអនុញ្ញាត ត្រូវបានគេលើកឡើងជាការជំទាស់បឋម តុលាការជំរះក្តី ត្រូវសំរេចលើអង្គហេតុ មុននឹងគិតពីអង្គច្បាប់ ។

២. រដ្ឋសមាជិកមានវិវាទ អាចប្តឹងជំទាស់ថា បណ្តឹងទាមទារគ្មានអង្គច្បាប់ជាក់ស្តែង មិនឱ្យលើសពី ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីការចេញសាលក្រមនៃតុលាការជំរះក្តី ។ រដ្ឋសមាជិកមានវិវាទ ក៏អាចប្តឹងជំទាស់ដែរថា បណ្តឹងទាមទារ គឺនៅក្រៅយុត្តាធិការ ឬសមត្ថកិច្ចនៃតុលាការជំរះក្តី ។ រដ្ឋសមាជិកមានវិវាទ ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាននូវមូលដ្ឋាននៃការជំទាស់នេះ ។

៣. តុលាការជំរះក្តី ត្រូវដោះស្រាយបណ្តឹងជំទាស់ទាំងឡាយ ជាសំនួរបឋម ក្រៅពីអង្គច្បាប់នៃបណ្តឹងទាមទារ ។ ភាគីមានវិវាទទាំងអស់ ត្រូវបានផ្តល់នូវកាលានុវត្តន៍ភាពដ៏សមហេតុផលមួយ ដើម្បីបង្ហាញពីទស្សនៈ និងការសង្កេតរបស់ពួកគេចំពោះតុលាការជំរះក្តី ។ ប្រសិនបើតុលាការជំរះក្តី សំរេចថា បណ្តឹងទាមទារនោះ គ្មានអង្គច្បាប់ជាក់ស្តែង ឬ ថាបណ្តឹងទាមទារមិននៅក្នុងយុត្តាធិការ ឬ សមត្ថកិច្ចនៃតុលាការជំរះក្តីទេ តុលាការជំរះក្តីត្រូវសំរេចក្តីទៅតាមនោះ ។

៤. ប្រសិនបើមានការធានា តុលាការជំរះក្តី អាចសម្រេចឱ្យភាគីឈ្នះនូវថ្លៃសមហេតុផល និងកំរៃ ដែលកើតឡើង ក្នុងការដាក់ពាក្យ ឬការប្រឆាំងជំទាស់ ។ ក្នុងការកំណត់ថា តើការសម្រេចនោះ ត្រូវបានធានា តុលាការជំរះក្តីត្រូវពិចារណាថា តើទាំងបណ្តឹងទាមទារ ឬបណ្តឹងជំទាស់ អាចយកជាការបាន ឬគ្មានអង្គច្បាប់ជាក់ស្តែង ហើយត្រូវផ្តល់ឱ្យភាគីមានវិវាទ នូវកាលានុវត្តន៍ភាពសមហេតុផលមួយ ដើម្បីផ្តល់មតិ ។

៥. ល្គឹកណា ភាគីមានវិវាទទាំងអស់ មិនយល់ព្រម ក្រៅពីនេះ តុលាការជំរះក្តី ត្រូវកំណត់ទីកន្លែងនៃមជ្ឈត្តវិនិច្ឆ័យ អនុលោមតាមវិធាននៃមជ្ឈត្តវិនិច្ឆ័យដែលអាចអនុវត្តបាន ប្រសិនបើ ទីកន្លែងនោះ ត្រូវស្ថិតក្នុងដែនដីនៃរដ្ឋមួយ ដែលជាភាគីនៃអនុសញ្ញា New York ។

៦. ពេលមានវិវាទវិនិយោគពាក់ព័ន្ធនឹងវិធានការ ដែលអាចជាវិធានការនៃពន្ធដារ រដ្ឋសមាជិកមាន វិវាទ និងរដ្ឋមិនមែនសមាជិកមានវិវាទ រួមទាំងតំណាងនៃរដ្ឋបាលពន្ធដាររបស់ពួកគេ ត្រូវរៀបចំនូវកិច្ចពិគ្រោះយោបល់គ្នាមួយ ដើម្បីកំណត់ថា តើវិធានការដែលចោទសួរនោះ ជាវិធានការពន្ធដារមួយឬយ៉ាងណា?

៧. ពេលអ្នកវិនិយោគមានវិវាទ ដាក់បណ្តឹងទាមទារថា រដ្ឋសមាជិកមានវិវាទ បានរំលោភលើមាត្រា ១៤ (ការដក ហូត និងសំណង) ដោយការអនុម័ត ឬអនុវត្តវិធានការពន្ធដារ រដ្ឋសមាជិកមានវិវាទ និងរដ្ឋមិនមែនសមាជិកមានវិវាទ នៅពេលបានទទួលសំណើពីរដ្ឋសមាជិកមានវិវាទនោះ ត្រូវរៀបចំកិច្ចពិគ្រោះយោបល់គ្នាមួយ ដើម្បីកំណត់ថា វិធានការពន្ធដារដែលចោទជាបញ្ហានោះ មានផលប៉ះពាល់ដូចគ្នាទៅនឹងការដកហូត ឬការធ្វើជាតូបនីយកម្មដែរឬទេ?

៨. តុលាការជំរះក្តីណាមួយ ដែលអាចត្រូវបានបង្កើតឡើងក្រោមផ្នែកនេះ ត្រូវពិនិត្យពិចារណាដោយយកចិត្តទុកដាក់ ចំពោះសេចក្តីសំរេចនៃរដ្ឋសមាជិកទាំងពីរ ក្រោមកថាខ័ណ្ឌ ៦ និង ៧។

៩. ប្រសិនបើរដ្ឋសមាជិកទាំងពីរ មិនផ្តួចផ្តើម ការពិគ្រោះយោបល់គ្នា យោងតាមកថាខ័ណ្ឌ ៦ និង៧ ឬក៏មិនអាចធ្វើសេចក្តីសំរេចរួមគ្នាបានទេ ក្នុងរយៈពេល ១៨០ថ្ងៃ គិតចាប់ពីថ្ងៃទទួលសំណើសុំពិគ្រោះយោបល់គ្នា យោងតាម មាត្រា ៣១ (ការពិគ្រោះយោបល់គ្នា) អ្នកវិនិយោគមានវិវាទ មិនត្រូវបានរាំងពីការស្នើសុំដាក់បណ្តឹងទាមទារ របស់ខ្លួន ទៅមជ្ឈត្តវិនិច្ឆ័យ អនុលោមតាមផ្នែកនេះឡើយ។

## មាត្រា ៣៧

## "ការបង្រួបបង្រួម"

ពេលបណ្តឹងទាមទារពីរ ឬ ច្រើន ត្រូវបានដាក់ចូលដោយឡែកពីគ្នា ទៅមជ្ឈត្តវិនិច្ឆ័យក្រោមមាត្រា ៣២ (បណ្តឹងទាមទារដោយអ្នកវិនិយោគនៃរដ្ឋសមាជិកមួយ) និងបណ្តឹងទាមទារទាំងឡាយ មានបញ្ហាច្បាប់ ឬ អង្គហេតុជារួម និងកើតឡើង ក្នុងព្រឹត្តិការណ៍ ឬកាលៈទេសៈប្រហាក់ប្រហែលគ្នា គ្រប់ភាគីមានវិវាទដែលពាក់ព័ន្ធ អាចនឹងយល់ព្រមបង្រួបបង្រួមចំពោះបណ្តឹងទាមទារទាំងនោះ ក្នុងស្មារតីណាមួយដែលពួកគេយល់ថាសមរម្យ។

## មាត្រា ៣៨

## "របាយការណ៍អ្នកជំនាញ"

ដោយគ្មានផលប៉ះពាល់ចំពោះការតែងតាំងនូវប្រភេទដទៃទៀតនៃអ្នកជំនាញ ដែលត្រូវបានផ្តល់សិទ្ធដោយវិធានមជ្ឈត្ត វិនិច្ឆ័យដែលអាចអនុវត្តបាន នៅពេលទទួលសំណើពីភាគីមានវិវាទនោះ សាលាជំរះក្តី អាចតែងតាំងអ្នកជំនាញ មួយរូប ឬច្រើនរូប ដើម្បីធ្វើរបាយការណ៍ចំពោះតុលាការ ជាលាយលក្ខណ៍អក្សរលើអង្គហេតុណាមួយពាក់ព័ន្ធ នឹងបញ្ហាបរិស្ថាន សុខភាពសាធារណៈ សុវត្ថិភាព និងបញ្ហាវិទ្យាសាស្ត្រដទៃទៀត ដែលបាន

លើកឡើងដោយ ភាគីមានវិវាទមួយ ក្នុងដំណើរការក្តី យោងទៅតាមវាក្យស័ព្ទ និងលក្ខខណ្ឌទាំងនោះ ដូចដែលភាគីមានវិវាទ អាចយល់ព្រម ។

## មាត្រា ៣៩

## "តម្លាភាពនៃដំណើរក្តីនៃមជ្ឈត្តវិនិច្ឆ័យ"

១. ផ្អែកតាមកថាខ័ណ្ឌ ២ និង ៣ រដ្ឋសមាជិកមានវិវាទ អាចផ្តល់ពត៌មានជាសាធារណៈអំពីសាលក្រម និងសេចក្តីសំរេចរបស់សាលាជំរះក្តី ។

២. ភាគីមានវិវាទណាមួយ ដែលមានបំណងប្រើប្រាស់ពត៌មានដែលជាពត៌មានសម្ងាត់ក្នុងការកាត់សេចក្តី ត្រូវតែប្រឹក្សាជាមួយសាលាជំរះក្តី ។ សាលាជំរះក្តី ត្រូវធ្វើការរៀបចំឱ្យបានសមរម្យដើម្បីការពារពត៌មានពីការផ្សព្វផ្សាយជាសាធារណៈ ។

៣. ពត៌មានណាមួយដែលកំណត់ជាក់លាក់ថាជាពត៌មានសម្ងាត់ ហើយបានផ្ញើជូនទៅសាលាជំរះក្តីឬភាគីមានវិវាទ ត្រូវបានការពារពីការផ្សព្វផ្សាយជាសាធារណៈ ។

៤. ភាគីមានវិវាទមួយ អាចផ្តល់ទៅបុគ្គលផ្សេងទៀតដោយផ្ទាល់នូវពត៌មានសម្ងាត់ ទាក់ទងនឹងដំណើរការនៃមជ្ឈត្តវិនិច្ឆ័យ ដែលមានសារសំខាន់សំរាប់ការរៀបចំនៃរឿងក្តីរបស់គេនោះ ប៉ុន្តែគេត្រូវបានតំរូវថាពត៌មានសម្ងាត់នោះ ត្រូវបានការពារ ។

៥. សាលាជំរះក្តី នឹងមិនតំរូវឱ្យរដ្ឋសមាជិកមួយ ផ្តល់ ឬ អនុញ្ញាតឱ្យទទួលបាននូវពត៌មានដែលផ្សព្វផ្សាយជាសាធារណៈ នូវអ្វីដែលនឹងរាំងស្ទះដល់ការអនុវត្តន៍ច្បាប់ ឬ ផ្ទុយនឹងច្បាប់នៃរដ្ឋសមាជិក ដែលការពារការសំងាត់របស់រដ្ឋាភិបាល ភាពជាឯកជនរបស់បុគ្គល ឬ កិច្ចការហិរញ្ញវត្ថុ និងគណនេយ្យនៃអតិថិជនឯកត្តជននៃស្ថាប័នហិរញ្ញវត្ថុ ឬដែលសាលាជំរះក្តីកំណត់ថា ជះឥទ្ធិពលអវិជ្ជមានដល់សន្តិសុខជាតិនោះឡើយ ។

៦. រដ្ឋសមាជិកមិនមានវិវាទ ត្រូវបានផ្តល់សិទ្ធិ ដើម្បីទទួលបាននូវអត្ថបទចម្លងនៃសេចក្តីប្រកាសរបស់មជ្ឈត្តវិនិច្ឆ័យ ដោយរាប់រងចំណាយខ្លួនឯងពីរដ្ឋសមាជិកមានវិវាទ មិនលើសពី ៣០ ( សាមសិប ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលឯកសារនោះ ត្រូវបានបញ្ជូនទៅឱ្យរដ្ឋសមាជិកមានវិវាទ ។ រដ្ឋសមាជិកមានវិវាទ ត្រូវជូនដំណឹងទៅគ្រប់រដ្ឋសមាជិកដទៃទៀត ស្តីពីការទទួលបាននូវសេចក្តីជូនដំណឹងនៃមជ្ឈត្តវិនិច្ឆ័យក្នុងរយៈពេល ៣០ ( សាមសិប ) ថ្ងៃ ។

## មាត្រា ៤០

## "ច្បាប់គ្រប់គ្រង"

១. ផ្អែកតាមកថាខ័ណ្ឌ ២ និង ៣ ពេលបណ្តឹងទាមទារ ត្រូវបានដាក់ជូនក្រោមមាត្រា ៣៣ ( ការដាក់ពាក្យបណ្តឹងទាមទារ) សាលាជំរះក្តី ត្រូវសំរេចបញ្ហាវិវាទ អនុលោមតាមកិច្ចព្រមព្រៀងនេះ តាមកិច្ចព្រមព្រៀងណាផ្សេងទៀត ដែលអាចអនុវត្តបាន រវាងរដ្ឋសមាជិក នឹងតាមវិធានដែលអាចអនុវត្តបាននៃច្បាប់អន្តរជាតិ នឹងពេលណាដែលអាចអនុវត្តបាន តាមច្បាប់ក្នុងស្រុកដែលពាក់ព័ន្ធណាមួយ នៃរដ្ឋសមាជិកមាន វិវាទ ។

២. សាលាជំរះក្តី តាមការយល់ឃើញផ្ទាល់ខ្លួន ឬ តាមសំណើសុំនៃភាគីមានវិវាទមួយ ត្រូវស្នើសុំឱ្យមានការបកស្រាយរួមនូវបញ្ញត្តិណាមួយនៃកិច្ចព្រមព្រៀងនេះ ដែលជាបញ្ហាក្នុងវិវាទ ។ រដ្ឋសមាជិក ត្រូវធ្វើជូនជាលាយលក្ខណ៍អក្សរនូវសេចក្តីសំរេចរួមណាមួយ ដែលប្រកាសពីការបកស្រាយរបស់ពួកគេ ទៅឱ្យសាលាជំរះក្តីក្នុងរយៈពេល ៦០ថ្ងៃ ចាប់ពីថ្ងៃដែលប្រគល់សំណើរ ។ ដោយគ្មានផលប៉ះពាល់ចំពោះកថាខ័ណ្ឌ ៣ ប្រសិនបើរដ្ឋសមាជិក បរាជ័យក្នុងការចេញនូវសេចក្តីសំរេចនេះក្នុងរយៈពេល ៦០ថ្ងៃនោះ ការបកស្រាយណាមួយដែលត្រូវដាក់ជូនដោយរដ្ឋសមាជិកមួយ ត្រូវធ្វើទៅភាគីមានវិវាទ និងសាលាជំរះក្តី ហើយសាលាជំរះក្តីត្រូវសំរេចបញ្ហាតាមការយល់ឃើញផ្ទាល់ខ្លួន ។

៣. សេចក្តីសំរេចរួមមួយនៃរដ្ឋសមាជិក ដែលប្រកាសពីការបកស្រាយរបស់ពួកគេចំពោះបញ្ញត្តិនៃកិច្ចព្រមព្រៀងនេះ ត្រូវបានសាលាជំរះក្តីចាត់ទុកជាផ្លូវការ ហើយសេចក្តីសំរេចណាមួយ ឬសាលក្រមណាមួយ ដែលត្រូវចេញដោយសាលាជំរះក្តីមួយ ត្រូវតែមានសង្គតភាពជាមួយសេចក្តីសំរេចរួមនោះ ។

## មាត្រា ៤១

## សេចក្តីសំរេចមជ្ឈត្តកិនិច្ឆ័យ "សាលក្រម"

១. ភាគីមានវិវាទទាំងអស់ អាចយល់ព្រមលើដំណោះស្រាយមួយនៃវិវាទនៅពេលវេលាណាមួយ មុនពេលសាលាជំរះក្តីចេញសាលក្រមស្ថាពររបស់ខ្លួន ។

២. នៅពេលសាលាជំរះក្តី ធ្វើការចេញសាលក្រមស្ថាពរជំទាស់នឹង ភាគីមានវិវាទណាមួយ នោះ សាលាជំរះក្តីអាចចេញសាលក្រម ( ដាច់ដោយឡែក ឬ ដោយបញ្ចូលគ្នា) សំរាប់តែ :

(ក) សំណងជាប្រាក់សំរាប់ការខូចខាត និងការប្រាក់ដែលត្រូវទទួលបាន និង

(ខ) បដិទាននៃទ្រព្យសម្បត្តិ ។ នៅក្នុងករណីនេះ សាលក្រមត្រូវបញ្ជាក់ថា រដ្ឋសមាជិកមានវិវាទ អាចទូទាត់សំណងជាប្រាក់សំរាប់ការខូចខាត និងការប្រាក់ដែលត្រូវទទួលបាន ជំនួសឱ្យបដិទាន ។

៣. សាលាជំរះក្តី អាចចេញសាលក្រមផងដែរ ចំពោះតម្លៃ និងកំរៃរបស់មេធាវី អនុលោមតាមកិច្ចព្រមព្រៀងនេះ និងវិធានមជ្ឈត្តវិនិច្ឆ័យទាំងឡាយណាដែលអាចអនុវត្តបាន ។

៤. សាលាជំរះក្តី មិនអាចចេញសាលក្រមស្តីពីកាខូចខាតជាលក្ខណៈទណ្ឌកម្មឡើយ ។

៥. សាលក្រម ដែលចេញដោយសាលាជំរះក្តីមួយ ពុំមានជាប់ជាកាតព្វកិច្ចឡើយ លើកលែងតែរវាងភាគីមានវិវាទ និងពាក់ព័ន្ធករណីដោយឡែក ។

៦. ផ្អែកតាមកថាខ័ណ្ឌ ៧ និងនីតិវិធីត្រួតពិនិត្យឡើងវិញដែលអាចអនុវត្តបាន សំរាប់ការចេញនូវសាលក្រមបណ្តោះអាសន្ន ភាគីមានវិវាទ ត្រូវអនុវត្ត និងប្រតិបត្តិតាមសាលក្រមដោយគ្មានពន្យាពេលឡើយ[១៥] ។

៧. ភាគីមានវិវាទ មិនអាចស្វែងរកការអនុវត្តន៍សាលក្រមស្ថាពរបានឡើយ រហូតដល់ :

(ក) ក្នុងករណីនៃសាលក្រមស្ថាពរក្រោមអនុសញ្ញានៃ ICSID:

(i) ១២០ (មួយរយម្ភៃ) ថ្ងៃ បានកន្លងទៅ ចាប់ពីកាលបរិច្ឆេទដែលសាលក្រមត្រូវបានចេញ និងគ្មានភាគីមានវិវាទណា បានស្នើសុំធ្វើការសើរើ ឬ ធ្វើមោឃភាពនៃសាលក្រម ឬ

(ii) ដំណើការសើរើ ឬ ដំណើរការធ្វើមោឃភាព បានត្រូវបញ្ចប់ជាស្ថាពរ ។

(ខ) ក្នុងករណីនៃសាលក្រមស្ថាពរក្រោម វិធានជាយន្តការបន្ថែមរបស់ ICSID វិធានមជ្ឈត្តវិនិច្ឆ័យនៃ UNCITRAL ឬ វិធានដែលបានជ្រើសរើសដោយយោងដល់មាត្រា ៣៣ (១) (ង) :

(i) ៩០ (កៅសិប) ថ្ងៃ បានកន្លងទៅ ចាប់ពីកាលបរិច្ឆេទដែលសាលក្រម ត្រូវបានចេញ ហើយគ្មានភាគីមានវិវាទណា បានចាប់ផ្តើមនូវដំណើរការដើម្បីសើរើ ធ្វើឱ្យទៅជាមោឃៈ ឬ ទុកជាមោឃៈនៃសាលក្រម ឬ

(ii) តុលាការមួយ បានច្រានចោល ឬ អនុញ្ញាតឱ្យមានការសើរើ ធ្វើឱ្យទៅជាមោឃៈនៃសាលក្រម និងគ្មានការប្តឹងឧទ្ធរណ៍ ។

---

[១៥] ភាគីទាំងអស់ យល់ថាអាចនឹងមានដំណើរការរដ្ឋបាល និងច្បាប់ក្នុងស្រុក ដែលត្រូវតែធ្វើការអង្កេត មុនពេល ដែលសាលក្រម អាចត្រូវបានប្រតិបត្តិតាម ។

៨. បណ្តឹងទាមទារដែលត្រូវបានដាក់ជូនសំរាប់ធ្វើមជ្ឈត្តវិនិច្ឆ័យក្រោមផ្នែកនេះ ត្រូវបានកំណត់ថា កើតចេញពីទំនាក់ទំនងពាណិជ្ជកម្ម ឬចម្លងការសំរាប់គោលបំណងនៃមាត្រា ១ នៃអនុសញ្ញាទីក្រុងញូវយ៉ក ។

៩. រដ្ឋសមាជិកនីមួយៗ ត្រូវអនុវត្តសាលក្រមនៅក្នុងដែនដីរបស់ខ្លួន ។

## ផ្នែក "គ"

## មាត្រា ៤២

## "ការរៀបចំស្ថាប័ន"

១. ក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន (AIA Council) ដូចដែលបានបង្កើតឡើងដោយរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន (AEM) ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីតំបន់វិនិយោគអាស៊ាន មានភារកិច្ចទទួលខុសត្រូវសំរាប់អនុវត្តកិច្ចព្រមព្រៀងនេះ ។

២. គណៈកម្មាធិការសម្របសំរួលអាស៊ាន ស្តីពីការវិនិយោគ ("CCI") ដូចដែលបានបង្កើតឡើង ដោយក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ហើយមានឧត្តមមន្ត្រីទទួលបន្ទុកសំរាប់ការងារវិនិយោគ និងឧត្តមមន្ត្រីមកពីស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ត្រូវជួយក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន ។ គណៈកម្មាធិការសម្របសម្រួលអាស៊ានស្តីពីការវិនិយោគ ត្រូវរាយការណ៍ជូនក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន តាមរយៈកិច្ចប្រជុំឧត្តមមន្ត្រីសេដ្ឋកិច្ច ("SEOM") ។ លេខាធិការដ្ឋានអាស៊ាន ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានឱ្យក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន និងគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពីការវិនិយោគ ។

៣. មុខងារ នៃក្រុមប្រឹក្សាតំបន់វិនិយោគអាស៊ាន ត្រូវ :

(ក) ផ្តល់ការណែនាំជាគោលនយោបាយស្តីពីបញ្ហាវិនិយោគក្នុងតំបន់ និងសកលលោក ទាក់ទងនឹងការជំរុញ កិច្ចសំរួល ការការពារ និងធ្វើសេរីភាវូបនីយកម្មវិនិយោគ

(ខ) មើលការខុសត្រូវ សម្របសម្រួល និងពិនិត្យឡើងវិញនូវការអនុវត្តន៍នៃកិច្ចព្រមព្រៀងនេះ

(គ) ធ្វើបច្ចុប្បន្នភាពជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន ស្តីពីការអនុវត្តន៍ និងប្រតិបត្តិការនៃកិច្ចព្រមព្រៀងនេះ

(ឃ) ពិនិត្យ និងផ្តល់អនុសាសន៍ជូនរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន លើការធ្វើវិសោធនកម្មណាមួយ ចំពោះកិច្ចព្រមព្រៀងនេះ

(ង) ផ្តល់កិច្ចសំរួលដល់ការជៀសវាង និងការដោះស្រាយនៃវិវាទដែលកើតឡើងពីកិច្ចព្រមព្រៀង នេះ

(ច) គ្រប់គ្រង និងសម្របសម្រួលការងារនៃគណៈកម្មាធិការសម្របសម្រួលអាស៊ាន ស្តីពីការវិនិយោគ

(ឆ) អនុម័តសេចក្តីសំរេចចាំបាច់ណាមួយ និង

(ជ) អនុវត្តភារកិច្ចដទៃទៀត ដែលរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន អាចយល់ព្រម

## មាត្រា ៤៣

## "ការពិគ្រោះយោបល់គ្នាដោយរដ្ឋសមាជិក"

រដ្ឋសមាជិកទាំងអស់ យល់ព្រមដើម្បីពិគ្រោះយោបល់គ្នាទៅវិញទៅមក នៅពេលមានការស្នើសុំពីរដ្ឋសមាជិកណាមួយ លើបញ្ហាណាមួយពាក់ព័ន្ធនឹងវិនិយោគដោយកិច្ចព្រមព្រៀងនេះ ឬ បញ្ហាដទៃទៀត ដែលមានផលប៉ះពាល់ដល់ការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤៤

## "ទំនាក់ទំនងនឹងកិច្ចព្រមព្រៀងដទៃទៀត"

គ្មានអ្វីក្នុងកិច្ចព្រមព្រៀងនេះ ត្រូវបដិប្បញ្ញត្តិអំពីសិទ្ធិ និងកាតព្វកិច្ចដែលមានស្រាប់ នៃរដ្ឋសមាជិកមួយ ក្រោមកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតណាមួយ ដែលខ្លួនជាភាគីនោះទេ ។

## មាត្រា ៤៥

## "ឧបសម្ព័ន្ធ តារាងកាលវិភាគ និងលិខិតូបករណ៍នាពេលអនាគត"

កិច្ចព្រមព្រៀងនេះ ត្រូវរួមបញ្ចូលទាំង "ឧបសម្ព័ន្ធ" "តារាងកាលវិភាគ" និង មាតិការរឿងក្នុងនោះ ដែលត្រូវបង្កើតបានជាផ្នែកសំខាន់មួយនៃកិច្ចព្រមព្រៀងនេះ ព្រមទាំងគ្រប់លិខិតូបករណ៍ស្របច្បាប់ដែលត្រូវបានយល់ព្រមយោងតាមកិច្ចព្រមព្រៀងនេះ ។

## មាត្រា ៤៦

## "ការធ្វើវិសោធនកម្ម"

បញ្ញត្តិទាំងអស់នៃកិច្ចព្រមព្រៀងនេះ អាចត្រូវបានកែសម្រួល តាមរយៈការធ្វើវិសោធនកម្មដែលយល់ព្រមជាលាយលក្ខណ៍អក្សរទៅវិញទៅមក ដោយរដ្ឋសមាជិកទាំងអស់ ។

## មាត្រា ៤៧

## "ការរៀបចំអន្តរកាលនាក់ទងនឹងកិច្ចព្រមព្រៀង ASEAN IGA និងកិច្ចព្រមព្រៀង AIA"

១. បន្ទាប់ពីកិច្ចព្រមព្រៀងនេះ ចូលជាធរមាន កិច្ចព្រមព្រៀង ASEAN IGA និងកិច្ចព្រមព្រៀង AIA ត្រូវបានបញ្ចប់។

២. ថ្វីបើមានការបញ្ចប់នៃកិច្ចព្រមព្រៀង AIA បញ្ជីលើកលែងបណ្តោះអាសន្ន និងបញ្ជីវេទយិតភាព ចំពោះកិច្ចព្រមព្រៀង AIA ត្រូវអនុវត្តចំពោះប្បញ្ញត្តិនៃការធ្វើសេរីភាវូបនីយកម្មនៃកិច្ចព្រមព្រៀង ACIA ក្នុងទំរង់ដូចគ្នាបើចាំបាច់ (*mutatis mutandis*) រហូតដល់ពេលដែលបញ្ជីបំរុងទុកនៃកិច្ចព្រមព្រៀង ACIA ចូលជាធរមាន។

៣. ទាក់ទងនឹងការវិនិយោគស្ថិតក្នុងវិសាលភាពនៃកិច្ចព្រមព្រៀងនេះ ក៏ដូចជាក្នុងកិច្ចព្រមព្រៀង ASEAN IGA ឬ នៅក្នុងកិច្ចព្រមព្រៀងនេះ និងកិច្ចព្រមព្រៀង AIA អ្នកវិនិយោគនៃការវិនិយោគទាំងនេះ អាចជ្រើសរើសដើម្បីអនុវត្តប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះទាំងមូល ឬ ប្បញ្ញត្តិនៃកិច្ចព្រមព្រៀង ASEAN IGA ទាំងមូល ឬ ប្បញ្ញត្តិនៃកិច្ចព្រមព្រៀង AIA ទាំងមូល សំរាប់រយៈពេល ៣ (បី) ឆ្នាំ បន្ទាប់ពីការបញ្ចប់នៃកិច្ចព្រមព្រៀង ASEAN IGA និងកិច្ចព្រមព្រៀង AIA។

## មាត្រា ៤៨

## "ការចូលជាធរមាន"

១. កិច្ចព្រមព្រៀងនេះ នឹងចូលជាធរមានបន្ទាប់ពីរដ្ឋសមាជិកទាំងអស់ បានជូនដំណឹង ឬ ក្នុងករណីចាំបាច់ តំកល់ទុកនូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ន ជាមួយ អគ្គលេខាធិការអាស៊ាន ដែលមិនត្រូវលើសពី ១៨០ (មួយរយប៉ែតសិប) ថ្ងៃ បន្ទាប់ពីការចុះហត្ថលេខានៃកិច្ចព្រមព្រៀងនេះ។

២. អគ្គលេខាធិការអាស៊ាន ត្រូវជូនដំណឹងភ្លាមទៅរដ្ឋសមាជិកទាំងអស់ ស្តីពីការជូនដំណឹង ឬការតំកល់ទុកនូវលិខិតូបករណ៍នៃការផ្តល់សច្ចាប័ននីមួយៗ ដែលមានចែងក្នុងកថាខ័ណ្ឌទី១ ។

## មាត្រា ៤៩

កិច្ចព្រមព្រៀងនេះ ត្រូវតំកល់ទុកជាមួយ អគ្គលេខាធិការអាស៊ាន ដែលត្រូវចាត់ចែងចម្លងជូនជាផ្លូវការភ្លាមៗ ទៅជូនរដ្ឋជាសមាជិកនីមួយៗ។

ដើម្បីជាសក្ខីភាពនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់នៃរដ្ឋសមាជិកទាំងអស់ ដែលបានទទួលសិទ្ធិអំណាចគ្រប់គ្រាន់ពីរដ្ឋាភិបាលរៀងៗខ្លួន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាននេះ ។

ធ្វើនៅ ចាអាម ព្រះរាជាណាចក្រថៃឡង់ដ៍ ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ២០០៩ ក្នុងច្បាប់ដើមតែមួយ ជាភាសាអង់គ្លេស ។

| | |
|---|---|
| សំរាប់ ព្រុយណេដារូសាឡឹម | LIM JOCK SENG<br>រដ្ឋមន្ត្រីទី២ ក្រសួងការបរទេស និងពាណិជ្ជកម្ម |
| សំរាប់ ព្រះរាជាណាចក្រកម្ពុជា | ចម ប្រសិទ្ធ<br>ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម |
| សំរាប់ សាធារណរដ្ឋឥណ្ឌូនេស៊ី | MARI ELKA PANGESTU<br>រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម |
| សំរាប់ សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ | NAM VIYAKETH<br>រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម |
| សំរាប់ ម៉ាឡេស៊ី | TAN SRI MUHYIDDIN YASSIN<br>រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្មអន្តរជាតិ និងឧស្សាហកម្ម |
| សំរាប់ សហភាពមីយ៉ាន់ម៉ារ | U SOE THA<br>រដ្ឋមន្ត្រី ក្រសួងផែនការជាតិ និងអភិវឌ្ឍន៍សេដ្ឋកិច្ច |
| សំរាប់ សាធារណរដ្ឋហ្វីលីពីន | PETER B. FAVILA<br>រដ្ឋលេខាធិការ នៃពាណិជ្ជកម្ម និងឧស្សាហកម្ម |
| សំរាប់ សាធារណរដ្ឋសិង្ហបុរី | LIM HNG KIANG<br>រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្ម |
| សំរាប់ ព្រះរាជាណាចក្រថៃឡង់ដ៍ | |
| សំរាប់ សាធារណរដ្ឋសង្គមនិយមវៀតណាម | VU HUY HOANG<br>រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្ម |

## ឧបសម្ព័ន្ធ ១

## ការអនុម័តគំរោងជាលាយលក្ខណ៍អក្សរ

ពេលត្រូវឱ្យមានការអនុម័តគំរោងជាក់លាក់ជាលាយលក្ខណ៍អក្សរ សំរាប់ដែនវិនិយោគ ដោយគោលនយោបាយជាតិ បទប្បញ្ញត្តិ និងច្បាប់ក្នុងស្រុករបស់រដ្ឋសមាជិកមួយ រដ្ឋសមាជិកនោះ ត្រូវ :

(ក) ជូនដំណឹងទៅគ្រប់រដ្ឋសមាជិកដទៃទៀត តាមរយៈលេខាធិការដ្ឋានអាស៊ាន ពីទំនាក់ទំនងលំអិត នៃអាជ្ញាធរមានសមត្ថកិច្ចដែលទទួលខុសត្រូវសំរាប់ផ្តល់ការអនុម័តទាំងនោះ

(ខ) កំណត់ និងជូនដំណឹងទៅអ្នកដាក់សំណើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល ១ (មួយ) ខែ ក្នុងករណីពាក្យស្នើសុំមានលក្ខណៈមិនពេញលេញ ចាប់គិតពីកាលបរិច្ឆេទនៃការទទួលពាក្យសុំនូវរាល់ពត៌មានបន្ថែម ដែលជាតំរូវការ

(គ) ជូនដំណឹងទៅអ្នកដាក់សំណើរសុំជាលាយលក្ខណ៍អក្សរថា ការវិនិយោគ ត្រូវបានអនុម័តជាក់លាក់ ឬ បដិសេធ ក្នុងរយៈពេល ៤ (បួន) ខែ បន្ទាប់ពីកាលបរិច្ឆេទដែល អាជ្ញាធរមានសមត្ថកិច្ចទទួលសំណើសុំគ្រប់គ្រាន់ហើយនោះ និង

(ឃ) ជូនដំណឹងទៅអ្នកដាក់សំណើសុំជាលាយលក្ខណ៍អក្សរ ក្នុងករណីសំណើសុំត្រូវបានបដិសេធ នូវមូលហេតុនៃការបដិសេធទាំងនោះ ។ អ្នកដាក់សំណើសុំ មានឱកាសដាក់សំណើសុំជាថ្មីមួយទៀត តាមការពិនិត្យពិចារណារបស់អ្នកស្នើសុំនោះ ។

## ឧបសម្ព័ន្ធ ២

## ("ការដកហូត និងសំណង")

១. សកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធ ដោយរដ្ឋសមាជិកមួយ មិនអាចចាត់ទុកថាជាការដកហូតបានឡើយ ល្គឹកណា វាមិនជ្រៀតជ្រែកជាមួយនឹងសិទ្ធិនៃទ្រព្យសម្បត្តិរូបីយ និងអរូបីយ ឬផលប្រយោជន៍នៃទ្រព្យសម្បត្តិ ក្នុងដែនវិនិយោគទេនោះ។

២. មាត្រា ១៤(១) លើកឡើងនូវស្ថានភាពចំនួនពីរ :

(ក) ស្ថានភាពទី១ គឺពេលការវិនិយោគមួយ ត្រូវបានធ្វើជាតូបនីយកម្ម ឬត្រូវធ្វើការ ដកហូតដោយផ្ទាល់ តាមរយៈការផ្ទេរជាផ្លូវការនូវសិទ្ធិជាកម្មសិទ្ធ ឬការរឹបអូសយកទាំងស្រុង និង

(ខ) ស្ថានភាពទី២ គឺពេលសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធ ដោយរដ្ឋសមាជិកមួយមានផលប៉ះពាល់ដូចគ្នាទៅនឹងការដកហូតដោយផ្ទាល់ ដោយគ្មានការផ្ទេរជាផ្លូវការនូវសិទ្ធិជាកម្មសិទ្ធ ឬការរឹបអូសទាំងស្រុង។

៣. ការកំណត់ថាតើសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធ ដោយរដ្ឋសមាជិក ក្នុងស្ថានភាពពិតជាក់ស្តែងមួយ ចាត់ទុកថា ជាការដកហូតនៃប្រភេទដែលបានយោងនៅក្នុងអនុកថាខ័ណ្ឌ ២(ខ) តំរូវឱ្យមានការស៊ើបអង្កេតយកអង្គហេតុជាមូលដ្ឋាន តាមករណី ដែលត្រូវពិភាគ ក្នុងចំណោមកត្តាដទៃទៀត :

(ក) ឥទ្ធិពលសេដ្ឋកិច្ចនៃសកម្មភាពរបស់រដ្ឋាភិបាល ថ្វីបើអង្គហេតុ ដែលសកម្មភាពមួយ ឬកំរងនៃសកម្មភាពពាក់ព័ន្ធដោយរដ្ឋសមាជិកមួយ មានផលប៉ះពាល់មិនល្អលើតម្លៃសេដ្ឋកិច្ចនៃការវិនិយោគមួយ ដោយឡែក មិនមានន័យថា ការដកហូតបានកើតឡើងនោះទេ

(ខ) ថាតើសកម្មភាពរបស់រដ្ឋាភិបាល បានរំលោភលើការប្តេជ្ញាជាលាយលក្ខណ៍អក្សររបស់រដ្ឋាភិបាលចំពោះអ្នកវិនិយោគ មិនថាជាកិច្ចសន្យា អាជ្ញាប័ណ្ណ ឬឯកសារច្បាប់ដទៃទៀត និង

(គ) ចរិតលក្ខណៈនៃសកម្មភាពរបស់រដ្ឋាភិបាល រាប់បញ្ចូលទាំងគោលបំណងនៃសកម្មភាពនោះ និងថាតើសកម្មភាព មានវិសម្មាមាត្រចំពោះគោលបំណងសារធារណៈ យោងតាមមាត្រា ១៤(១) ដែរឬទេ?

៤. វិធានការដែលគ្មានការរើសអើងនៃរដ្ឋសមាជិកមួយ ដែលត្រូវបានកំណត់ និងអនុវត្ត ដើម្បីការពារគោលបំណងសុខមាលភាពសាធារណៈស្របច្បាប់ ដូចជាសុខភាពសាធារណៈ សុវត្ថិភាព និងបរិស្ថាន ពុំបានចាត់ទុកថា ជាការដកហូតនៃប្រភេទដែលយោងដល់អនុកថាខ័ណ្ឌ ២(ខ) ឡើយ។